**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥១៣ សហវ.ប្រក

# ប្រកាស
# ស្ដីពី
# ការដាក់ឱ្យអនុវត្ត
# គោលការណ៍ណែនាំស្ដីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស០១៧/០៥០៨/រកម/ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ៨៧៤ សហវ.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom . Khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666

- បានឃើញយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥ ដែលបានទទួលការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពី *ការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត* ដូចមានខ្លឹមសារភ្ជាប់មកជាមួយប្រកាសនេះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាព និងកែតម្រូវគោលការណ៍ណែនាំនេះ តាមការចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការដាក់ឱ្យអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ២ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំថវិកាកម្មវិធីដោយផ្អែកលើគោលការណ៍ណែនាំនេះ។

**ប្រការ ៣ .-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំថវិកាកម្មវិធី

# សម្រាប់រដ្ឋបាលរាជធានី ខេត្ត

ឆ្នាំ ២០២០

# មាតិកា


**សន្ទានុក្រម**

**ផ្នែកទី ១- សេចក្តីផ្តើម**......................................................................................... ១

**ផ្នែកទី ២ - អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី**.....................................................៣

**ផ្នែកទី ៣- ដំណើរការនៃការរៀបចំថវិកាកម្មវិធី**..............................................................៥

**ជំហានទី១-** ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិកា.....................................................៥

**ជំហានទី២-** វិធីសាស្ត្របង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព.....៥

**ជំហានទី៣-** វិធីសាស្ត្រកំណត់គោលបំណងនៃរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព ..៧

**ជំហានទី៤-** វិធីសាស្ត្រក្នុងការកំណត់ខ្សែសង្វាក់លទ្ធផល...............................................១២

**ជំហានទី៥-** ពិនិត្យឡើងវិញលើឡូជីកនៃការកសាងរចនាសម្ព័ន្ធកម្មវិធី................................១៩

**ជំហានទី៦-** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ.........................................................២០

**ជំហានទី៧-** វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី...............................២៧

**ជំហានទី៨-** ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង...............................៣៣

**ផ្នែកទី ៤- ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា** ...............................................៣៧

**ផ្នែកទី៥-ឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២**

# សន្ទានុក្រម

| ល.រ | ពាក្យគន្លឹះ | Key Words | អត្ថន័យ |
|---|---|---|---|
| ១ | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩- ២០២៥ | Subnational Administration-Budget System Reform Strategy (SNA-BSRS) | សំដៅដល់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិរយៈពេលវែង និងគ្រប់ជ្រុងជ្រោយ ដោយបានកំណត់អំពីទិសដៅនិងក្របខ័ណ្ឌពេលវេលាច្បាស់លាស់និងបានដាក់ចេញផែនការសកម្មភាពកែទម្រង់តាមអភិក្រមសាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព ស្របតាមសមត្ថភាព និងតថភាពជាក់ស្តែងនៃកម្ពុជា។ |
| ២ | ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត | Capital and Province/ Budget Strategic Plan (CP/BSP) | សំដៅលើផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំរំកិលត្រូវបានរៀបចំប្រចាំឆ្នាំ ដោយមានលក្ខណៈសមាហរណកម្មដែលជាឧបករណ៍ផ្សារភ្ជាប់ទំនាក់ទំនងគោលនយោបាយជាតិជាមួយនឹងផែនការយុទ្ធសាស្ត្រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើឱ្យផែនការថវិកាមានការផ្សារភ្ជាប់ជាមួយនឹងគោលបំណងគោលនយោបាយតែមួយ។ |
| ៣ | ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | Five-Year Development Plan of Subnational Administration | សំដៅដល់ផែនការអភិវឌ្ឍន៍ ដែលត្រូវបានរៀបចំ៥ឆ្នាំម្តងដោយរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ វាជាការរៀបចំផែនការតាមវិស័យ ដែលផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ចំពោះអាទិភាពតាមវិស័យនៅមូលដ្ឋាន និងធ្វើជាមគ្គុទេសក៍សម្រាប់កម្រិតអនុវត្ត និងតម្រែតម្រង់ការផ្តល់សេវារបស់ខ្លួនឱ្យឆ្លើយតបទៅនឹងអាទិភាពជាតិ។ |
| ៤ | កម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | Three-Year Rolling Investment Program of Subnational Administration | សំដៅដល់ការរៀបចំកម្មវិធីវិនិយោគរយៈពេលមធ្យម (៣ឆ្នាំ) នៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ វាជាការរៀបចំផែនការវិនិយោគតាមវិស័យ ដែលផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ចំពោះអាទិភាពតាមវិស័យនៅមូលដ្ឋាន និងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ |

| | | | |
|---|---|---|---|
| ៥ | ក្របខ័ណ្ឌថវិការយៈពេលមធ្យម | Medium-Term Budget Framework (MTBF) | សំដៅលើការរៀបចំក្របខ័ណ្ឌចំណូល ចំណាយថវិការយៈពេលមធ្យម(បីឆ្នាំ) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៦ | ថវិកាផ្តោតលើធាតុចូល | Input Base Budgeting | សំដៅដល់ការរៀបចំថវិកាផ្តោតទៅលើតម្រូវការធាតុចូលទៅតាមជំពូក គណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ |
| ៧ | ថវិកាកម្មវិធី | Program Budgeting | សំដៅដល់ការរៀបចំថវិកាផ្អែកលើកម្មវិធីច្បាស់លាស់ និងប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ។ |
| ៨ | ការធ្វើសមាហរណកម្មផែនការនីយកម្ម | Integration of Planning | សំដៅដល់ការធ្វើសុខដុមនីយកម្មកិច្ចដំណើរការធ្វើផែនការដែលក្នុងនោះរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នានិងប្រទាក់ក្រឡាគ្នាទៅវិញទៅមក ដោយការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ |
| ៩ | ការធ្វើសមាហរណកម្មផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | Integration of Program Activities at Subnational Levels | សំដៅដល់ការគ្រោងផែនការសកម្មភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានលក្ខណៈប្រមូលផ្តុំ ដោយតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ ដើម្បីគាំទ្រដល់អាទិភាពគោលនយោបាយនៅមូលដ្ឋាន ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យ និងអាទិភាពជាតិ។ |
| ១០ | ការតម្រឹម | Alignment | សំដៅលើការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័ន ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតដើម្បីសម្រេចបានសមិទ្ធផលជាអតិបរមា។ ក្នុងន័យនេះ នៅពេលរៀបចំផែនការ/កម្មវិធីរបស់ខ្លួន រដ្ឋបាលរាជធានី ខេត្តត្រូវពិនិត្យមើលផែនការឬវិស័យអាទិភាពដែលមន្ទីរជំនាញបានគ្រោង ។ប្រសិនបើជាពិនិត្យឃើញថា ផែនការ |

| | | | |
|---|---|---|---|
| | | | ឬវិស័យអាទិភាពនោះមានភាពចាំបាច់ ហើយមន្ទីរជំនាញរាជធានី ខេត្តមិនបានគ្រោង នោះរដ្ឋបាលរាជធានី ខេត្តអាចរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដើម្បីអនុវត្តសកម្មភាពនោះ។ |
| ១១ | បច្ច័យ | Impacts | សំដៅលើឥទ្ធិពលជាវិជ្ជមានស្របតាមម៉ូឌែលឡូជីកដែលជាការកំណត់លទ្ធផលចុងក្រោយពិតប្រាកដសម្រាប់កម្មវិធី (ឧ.ការថយចុះភាពក្រីក្រ,អត្រាអ្នកមានការងារធ្វើកើនឡើង...)។ ការធ្វើការវាយតម្លៃលើបច្ច័យ គឺមានរយៈពេល ៥ ឆ្នាំម្តង។ |
| ១២ | លទ្ធផលចុងក្រោយ | Outcomes | សំដៅដល់លទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំក្រោយពីការអនុវត្តបានពេញលេញនូវកម្មវិធីក្នុងរយៈពេលកំណត់មួយ។ |
| ១៣ | លទ្ធផលក្នុងឆ្នាំ | Outputs | សំដៅលើលទ្ធផលសម្រេចបាននូវសូចនាករ និងគោលដៅប្រចាំឆ្នាំនៃការអនុវត្តចង្កោមសកម្មភាព និងអនុវត្តកម្មវិធីស្របតាមការទទួលខុសត្រូវនៃរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធីប្រចាំឆ្នាំ។ |
| ១៤ | ឡូជីកនៃកម្មវិធី | Program Logic | សំដៅលើការរៀបចំផែនការយុទ្ធសាស្ត្រដោយផ្សារភ្ជាប់នឹងសមិទ្ធកម្មទៅតាមឋានុក្រម (ឧ.សូចនាករសម្រាប់កម្រិតគោលបំណងគោលនយោបាយ និងកម្រិតកម្មវិធីគឺជា លទ្ធផលចុងក្រោយ រីឯកម្រិតអនុកម្មវិធីចុះក្រោមគឺលទ្ធផលក្នុងឆ្នាំ)។ |
| ១៥ | ក្របខ័ណ្ឌវាយតម្លៃ | Evaluation Framework | សំដៅដល់ការរៀបចំក្របខ័ណ្ឌអភិក្រមគ្រប់ជ្រុងជ្រោយមួយដើម្បីសម្រេចជំហានបន្ទាប់បាន លុះត្រាតែសម្រេចបានសមាសភាពជាមូលដ្ឋាន (ឧ.ដើម្បីអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មបាន លុះត្រាតែមានសមាសធាតុសំខាន់ត្រូវបានរៀបចំ រួមមាន ថវិកាកាន់តែទុកចិត្តបាន, មានប្រព័ន្ធFMIS, គុណភាពផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី)។ |

| | | | |
|---|---|---|---|
| ១៦ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | Key Performance Indicator Target (KPI Target) | សំដៅដល់កម្រិតនៃការរំពឹងទុកនៃសមិទ្ធកម្ម ដែលត្រូវបានកំណត់ជាលេខ, ភាគរយ, ពេលវេលា និងកន្លែងណាមួយដែលអាចជឿទុកចិត្តបានថានឹងសម្រេចបានក្នុងពេលវេលាជាក់លាក់ណាមួយ។ |
| ១៧ | សូចនាករសមិទ្ធកម្មគន្លឹះ | Key Performance Indicator (KPI) | សំដៅដល់ឧបករណ៍សម្រាប់ធ្វើការវាស់វែងវឌ្ឍនភាពនៃការអនុវត្តសកម្មភាព, លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។ សូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាគឺជាចំណុចវិជ្ជមានក្នុងការជំរុញឱ្យផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មឱ្យបានកាន់តែខ្លាំងឡើង ជាពិសេស បានធ្វើឱ្យដំណើរការរៀបចំ និងអនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាព និងគ្រប់គ្រងបាន។ |
| ១៨ | វិធីសាស្ត្រ SMART | SMART (Specific, Measurable Attainable Relevant Timeframe) | សំដៅដល់វិធីសាស្ត្រដើម្បីធានាថាលទ្ធផលចុងក្រោយ និងលទ្ធកម្មក្នុងឆ្នាំត្រូវបានរៀបចំ និងវាស់វែងដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ដែលមានលក្ខណៈ SMART (ជាក់លាក់, អាចវាស់វែង, អាចសម្រេចបាន, ពាក់ព័ន្ធ និងមានពេលកំណត់) ដើម្បីឆ្លើយតបទៅនឹងគោលដៅសមិទ្ធកម្មសមស្រប។ |
| ១៩ | មន្ត្រីបច្ចេកទេសថវិកា | Budget Technical Official | សំដៅដល់មន្ត្រីជំនាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជួយការគាំទ្រ និងសម្របសម្រួលផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម។ |
| ២០ | ក្រុមការងារថវិកា | Budget Working Group | សំដៅដល់ក្រុមការងាររបស់រដ្ឋបាលរាជធានី ខេត្ត ដែលទទួលការងារសម្របសម្រួលជាមួយនឹងគ្រប់ទីចាត់ការនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម។ |

*បញ្ជាក់៖ សន្ទានុក្រមនេះ គឺជាការប្រមូលផ្តុំ និងការពន្យល់ពាក្យបច្ចេកទេសខ្លះៗ ដែលបានប្រើប្រាស់ក្នុងគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីនេះ តែប៉ុណ្ណោះ។*

# ផ្នែកទី ១
# សេចក្តីផ្តើម

**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥** បានឆ្លុះបញ្ចាំងនូវគោលបំណងនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាគន្លឹះៗ ដើម្បីធានារាល់ការចំណាយសាធារណៈទាំងអស់ គឺឈានឆ្ពោះទៅរកការសម្រេចបានគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងវិមជ្ឈការកាន់តែប្រសើរឡើង។ ការអនុវត្តផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី នឹងជួយពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងថវិកាទៅនឹងគោលនយោបាយកាន់តែមានប្រសិទ្ធភាព និងបានបង្កើតជាមូលដ្ឋានកាន់តែរឹងមាំសម្រាប់ឈានទៅអនុវត្តប្រព័ន្ធថវិកាផ្តោតលើគណនេយ្យភាពសមិទ្ធកម្ម ដែលជាទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដំណាក់កាលទី ៤។

*«គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត»* ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានគោលដៅពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតរវាងគោលនយោបាយជាមួយនឹងការរៀបចំថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត) ជាមួយនឹងផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដំណើរការនៃការផ្សារភ្ជាប់គ្នារវាងផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងអាទិភាពជាតិតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិកាន់តែមានប្រសិទ្ធភាពនឹងធ្វើឱ្យការប្រើប្រាស់ធនធាន ដែលមានកម្រិតដើម្បីសម្រេចបានសមិទ្ធផលជាអតិបរមា។ តាមទិសដៅនេះរចនាសម្ព័ន្ធកម្មវិធីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានកែសម្រួលឡើងវិញ ដើម្បីឱ្យមានសង្គតិភាពជាមួយវិស័យអាទិភាពថ្នាក់ជាតិ។ សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវបានរៀបចំឱ្យមានមានលក្ខណៈ SMART (ជាក់លាក់, អាចវាស់វែង, អាចសម្រេចបាន, ពាក់ព័ន្ធ និងមានពេលកំណត់) ដែលអាចឆ្លើយតបទៅនឹងគោលដៅនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។

ដើម្បីសម្រេចបានទិសដៅខាងលើនេះ ចាំបាច់ត្រូវមានការសម្របសម្រួល និងពិគ្រោះយោបល់ក្នុងចំណោមគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានសមាសភាពពីមន្ទីរជំនាញរាជធានី ខេត្ត និងភាគីពាក់ព័ន្ធ

ទាំងអស់ នឹងត្រូវដើរតួនាទីសំខាន់ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ ជាមួយគ្នានេះ ការបង្កើតឱ្យមានយន្តការគាំទ្រពីថ្នាក់ជាតិ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានភាពចាំបាច់ណាស់។ តាមរយៈនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំក្រុមការងារបច្ចេកទេសកម្រិតថ្នាក់ជាតិមួយ ហៅថា *«មន្ត្រីបច្ចេកទេសថវិកា»* ដើម្បីជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ដោយឡែក រដ្ឋបាលរាជធានី ខេត្ត ក៏ត្រូវត្រៀមរៀបចំ *«ក្រុមការងារថវិកា»* ដើម្បីផ្តល់ការសហការលើកិច្ចការនេះផងដែរ។

*«គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត»* ជាមគ្គុទ្ទេសក៍សម្រាប់ជួយណែនាំអំពីវិធីសាស្ត្រនៃការរៀបចំថវិកាកម្មវិធីដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីធានាថាកម្មវិធី ដែលបានកសាងឈានទៅសម្រេចបានគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំនេះ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដើម្បីកែលម្អ និងធានាឱ្យការអនុវត្តថវិកាកម្មវិធីមានភាពស័ក្តិសិទ្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តធ្វើការកែលម្អគោលការណ៍ណែនាំនេះពីមួយឆ្នាំទៅមួយឆ្នាំទៅតាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែងដើម្បីឱ្យគោលការណ៍ណែនាំនេះកាន់តែមានសុក្រឹតភាព ពិសេសធានាបាននូវការអនុវត្តថវិកាកម្មវិធីមួយដែលសមស្របសម្រាប់កម្ពុជា។

គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី ចែកចេញជា៥ផ្នែក រួមមាន÷ **ផ្នែកទី១**-សេចក្តីផ្តើម **ផ្នែកទី២**-អត្ថប្រយោជន៍នៃកាអនុវត្តថវិកាកម្មវិធី **ផ្នែកទី៣**-ដំណើរការនៃការរៀបចំថវិកាកម្មវិធី **ផ្នែកទី៤**-ការពិនិត្យតាមដានវាយតម្លៃ ការអនុវត្ត និងការធ្វើរបាយការណ៍ និង **ផ្នែកទី៥**-ឧបសម្ព័ន្ធ។

# ផ្នែកទី ២
# អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី

**ថវិកាកម្មវិធី** គឺជាការរៀបចំថវិកាប្រចាំឆ្នាំដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចបានផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាទិភាពជាតិតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ។ ការរៀបចំថវិកាកម្មវិធី គឺជាដំណាក់កាលទី២ បន្ទាប់ពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

ថវិកាកម្មវិធី ត្រូវមានសូចនាករសមិទ្ធកម្មគន្លឹះ (KPI) សម្រាប់វាស់វែង និងធ្វើរបាយការណ៍លទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី និងលទ្ធផលក្នុងឆ្នាំ (Output) នៃអនុកម្មវិធី និងចង្កោមសកម្មភាព។ ថវិកាកម្មវិធីត្រូវកំណត់ឱ្យបានច្បាស់នូវធាតុចូល ដែលរួមមាន ចំណាយចរន្ត និងចំណាយមូលធនដែលចាំបាច់សម្រាប់ការអនុវត្តកម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព។

ថវិកាកម្មវិធី នឹងផ្តល់ជាមធ្យោបាយដើម្បីធ្វើការពិនិត្យឡើងវិញអំពីការវិភាជន៍ធនធានដែលបានរៀបចំនៅក្នុងដំណាក់កាលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជាពិសេសផ្តល់លទ្ធភាពពិនិត្យ និងថ្លឹងថ្លែងឡើងវិញរវាងអាទិភាពគោលនយោបាយចាស់ និងគោលនយោបាយថ្មីនៅពេលរៀបចំថវិកាឆ្នាំបន្ទាប់។

ផ្ទុយទៅវិញ, ការរៀបចំថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជាការរៀបចំថវិកាដោយផ្តោតតែលើមូលដ្ឋានតម្រូវការធាតុចូលទៅតាមប្រភេទ ជំពូក គណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ ការរៀបចំថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាមិនអាចឱ្យយើងសម្រេចបានគោលបំណងគោលនយោបាយ ឬវិស័យអាទិភាពបានទាំងស្រុងទេ ពីព្រោះការរៀបចំថវិកាតាមបន្ទាត់មាតិកាថវិកាអនុញ្ញាតឱ្យយើងកត់ត្រាបានតែមុខសញ្ញាចំណាយតាមបែបសេដ្ឋកិច្ច ដែលបម្រើតែគោលដៅរបាយ-ការណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។ ថវិកាតាមបន្ទាត់មាតិកាថវិកានេះ មិនបានជួយផ្សារភ្ជាប់ទំហំចំណាយលើធាតុចូលដែលបានផ្តល់ទៅនឹងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរំពឹងទុកនោះទេ។ ជាលទ្ធផល, ការអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា បានបង្កើតជាផ្នត់គំនិតឱ្យរដ្ឋបាលរាជធានី ខេត្ត ទាមទារកំណើនថវិកាប្រចាំឆ្នាំដោយផ្អែកតែទៅលើថវិកាឆ្នាំកន្លងមក ដោយមិនបានយកចិត្តទុកដាក់ដល់សមិទ្ធកម្មឡើយ។

ជារួម, ការអនុវត្តថវិកាកម្មវិធី នឹងបង្កើតបានជាមូលដ្ឋានគ្រឹះ សម្រាប់កែលម្អនូវកត្តាមួយចំនួនដូចខាងក្រោម÷

- ✓ ការរៀបចំផែនការថវិកាប្រចាំឆ្នាំ តាមរយៈការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ឬអាទិភាពតាមវិស័យ,
- ✓ លទ្ធផលចុងក្រោយ (Outcome) និងលទ្ធផលក្នុងឆ្នាំ (Output) ដែលរដ្ឋបាលរាជធានី ខេត្ត សម្រេចបានតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ ឆ្លើយតបទៅនឹងថវិកាដែលបានចំណាយ,
- ✓ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ត្រូវបានពង្រឹង ស្របតាមអាទិភាពនៃគោលនយោបាយរបស់រដ្ឋាភិបាល,
- ✓ ការអនុវត្តថវិកា ដើម្បីជួយពង្រឹង និងបង្កើតឱ្យមានបន្ទាត់គណនេយ្យភាព ដែលជាមូលដ្ឋានកាន់តែរឹងមាំសម្រាប់ឈានទៅអនុវត្តប្រព័ន្ធថវិកាផ្តោតលើគណនេយ្យភាពសមិទ្ធកម្ម, និង
- ✓ ការតាមដាន វាយតម្លៃ និងការធ្វើរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកា។

# ផ្នែកទី ៣
# ដំណើរការនៃការរៀបចំថវិកាកម្មវិធី

រដ្ឋបាលរាជធានី ខេត្ត ដោយមាន **«ក្រុមការងារថវិកា»** ជាអ្នកជួយសម្របសម្រួល ត្រូវរៀបចំថវិកាកម្មវិធីប្រចាំឆ្នាំរបស់ខ្លួនទៅតាមជំហានតីមួយៗ ដូចខាងក្រោម÷

## ៣.១ ជំហានទី១- ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត

ដើម្បីអាចរៀបចំថវិកាកម្មវិធីបានល្អ ចាំបាច់ត្រូវយល់ឱ្យបានច្បាស់នូវគោលដៅរបស់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ។ ***ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត*** គឺជាផែនការរយៈពេលបីឆ្នាំរំកិល តាមអភិក្រមពីក្រោមឡើងលើ ដែលត្រូវបានរៀបចំប្រចាំឆ្នាំ ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងគោលដៅតាមវិស័យ និងផែនការអភិវឌ្ឍន៍ ជាពិសេស កម្មវិធីវិនិយោគ៣ឆ្នាំរំកិល។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺជាដំណាក់កាលទី១នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ត្រូវចាប់ផ្តើមចន្លោះខែមេសា និងឧសភា។ នៅក្នុងដំណាក់កាលទី២នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ គឺការរៀបចំកញ្ចប់ថវិកាដែលត្រូវចាប់ផ្តើមពីខែ មិថុនា ដល់ខែ កញ្ញា។ នៅក្នុងដំណាក់កាលទី២នេះ ***«ក្រុមការងារថវិកា»*** ដែលត្រូវបានបង្កើតឡើងដោយរដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យមើលឡើងវិញរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងផែនការអន្តរាគមន៍របស់រដ្ឋបាលរាជធានី ខេត្តសាមី ដែលបានគ្រោងនៅក្នុងឆ្នាំទី១ (ឆ្នាំ n+1)នៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដែលត្រូវបានពិនិត្យ និងសម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដែលនឹងត្រូវរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ជាក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការថវិកាកម្មវិធីប្រចាំឆ្នាំ។

## ៣.២ ជំហានទី២- វិធីសាស្ត្របង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព

***(ជំហានទី២ នេះ ផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងជួរឈរទី១ នៃតារាងឧបសម្ព័ន្ធទី ១.១, ១.២ និង ១.៣ ដូចមានជូនភ្ជាប់មកជាមួយ)***

### ៣.២.១ ការកំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវ

ដើម្បីឱ្យការអនុវត្តថវិកាកម្មវិធីអាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព រដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវចំពោះកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាពនីមួយៗ។ តារាងទី ១ ខាងក្រោម ផ្តល់នូវគោលការណ៍ និងអនុសាសន៍មួយចំនួន សម្រាប់កំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវលើការអនុវត្តកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព។

***តារាងទី១÷ គោលការណ៍ និងអនុសាសន៍នៃការកំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវ***

| | **គោលការណ៍** | **អនុសាសន៍** |
|---|---|---|
| **កម្មវិធី** | ✓ កម្មវិធីមួយត្រូវមានគោលបំណងច្បាស់លាស់មួយ<br>✓ កម្មវិធីមួយត្រូវមានសូចនាករលទ្ធផលចុងក្រោយ (Outcome) យ៉ាងហោចណាស់មួយ<br>✓ រដ្ឋបាលរាជធានី ខេត្តគួរមានកម្មវិធីច្រើនបំផុតបួន | កម្មវិធីគួរទទួលខុសត្រូវដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **អនុកម្មវិធី** | ✓ ចំនួនអនុកម្មវិធី គួរសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់កម្មវិធី ជាពិសេស ដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់កម្មវិធី<br>✓ អនុកម្មវិធីមួយ គួរមានសូចនាករលទ្ធផលក្នុងឆ្នាំមួយ ឬច្រើន ដើម្បីរួមវិភាគទានសម្រេចបានគោលបំណងរួម និងលទ្ធផលចុងក្រោយនៃកម្មវិធីមួយ | អនុកម្មវិធី គួរទទួលខុសត្រូវដោយអភិបាលរង/ នាយករដ្ឋបាលស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **ចង្កោមសកម្មភាព** | ✓ ចង្កោមសកម្មភាព អាចមានចំនួនច្រើនដើម្បីសម្រេចបានអនុកម្មវិធីមួយ<br>✓ ចង្កោមសកម្មភាពមួយត្រូវមានសូចនាករលទ្ធផលក្នុងឆ្នាំយ៉ាងតិចមួយសម្រាប់វាស់វែងការអនុវត្តប្រចាំឆ្នាំ | ចង្កោមសកម្មភាពគួរទទួលខុសត្រូវដោយនាយករងរដ្ឋបាល/ នាយកទីចាត់ការ ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **សកម្មភាព** | ✓ សកម្មភាពអាចមានចំនួនច្រើនដើម្បីសម្រេច | គួរទទួលបន្ទុកដោយនាយករង |

| | | |
|---|---|---|
| | បានចង្អុលសកម្មភាពមួយ<br>✓ សកម្មភាពមួយត្រូវមានសូចនាករយ៉ាងតិចមួយសម្រាប់វាស់វែង។ | ទីចាត់ការ/ប្រធានការិយាល័យតាមវិស័យ |

*សម្គាល់÷សូមមើលបន្ថែមនៅក្នុងគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិការាជធានី ខេត្ត*

**៣.២.២ ការបង្កើតកម្មវិធី**

ដូចក្នុងតារាងទី២ខាងក្រោម គ្រប់រដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវមានគោលបំណងគោលនយោបាយចំនួន ១ និងមានកម្មវិធីចំនួន ៤។

*តារាងទី២÷ ទំនាក់ទំនងរវាងគោលបំណងគោលនយោបាយ និងកម្មវិធី*

| គោលបំណងគោលនយោបាយ | កម្មវិធី |
|---|---|
| ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍរដ្ឋបាលសាធារណៈ និងសេវាសាធារណៈរាជធានី ខេត្ត | ១. អភិវឌ្ឍវិស័យសេដ្ឋកិច្ច |
| | ២. ពង្រឹងវិស័យសង្គមកិច្ច |
| | ៣. លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ |
| | ៤. ពង្រឹងរដ្ឋបាលទូទៅ |

គ្រប់កម្មវិធីទាំងអស់ ដែលបានរៀបចំ ចាំបាច់ត្រូវមានគោលដៅច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការរៀបចំរចនាសម្ព័ន្ធអនុកម្មវិធី ចង្អុលសកម្មភាព និងសកម្មភាព និងធ្វើការតាមដាន និងវាស់វែងលើការសម្រេចបានលទ្ធផលចុងក្រោយ (Outcomes) នៃកម្មវិធីនីមួយៗ។

- ✓ **កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសេដ្ឋកិច្ច ដែលជាកម្មវិធីដើម្បីកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចជា÷ ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងចំណូល និងចំណាយ។ **ឧទាហរណ៍÷** ការកសាង និងការជួសជុលផ្លូវ, ប្រព័ន្ធលូ, ប្រឡាយទឹក និងផ្សេងៗ លើកលែងការកសាង និងការជួសជុលអាគាររដ្ឋបាល និងសួនច្បារសាធារណៈ។
- ✓ **កម្មវិធីទី២-ពង្រឹងវិស័យសង្គមកិច្ច÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសង្គមកិច្ច ដូចជា÷ ការលើកកម្ពស់វិស័យសង្គមកិច្ច (ដូចជា កីឡា, វប្បធម៌, អប់រំ, សុខាភិបាល និង

បរិស្ថាន) ការបង្កើនសេវាសាធារណៈតាមរយៈការជួយដល់សង្គម (ដូចជា ការទិញអង្ករឧបត្ថម្ភដល់ជនក្រីក្រ) និងការឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល។ ក្រៅពីនេះ កម្មវិធីទី២មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រើប្រាស់ដីធ្លី, ធានាចិរភាពបរិស្ថានល្អ, គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងបញ្ជីសារពើភ័ណ្ឌ។ **ឧទាហរណ៍÷** កែលម្អសួនសាធារណៈ ការប្រមូលសំរាម និងការស្តារប្រព័ន្ធប្រឡាយទឹកកខ្វក់។

- ✓ **កម្មវិធីទី៣-លើកកម្ពស់សន្តិសុខនិងសុវត្ថិភាពសាធារណៈ÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសន្តិសុខសាធារណៈ ដែលជាកម្មវិធីដើម្បីគាំទ្រសន្តិសុខសង្គម និងការទប់ស្កាត់បទល្មើសផ្សេងៗ។ **ឧទាហរណ៍÷** គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងគណៈបញ្ជាការឯកភាព។

- ✓ **កម្មវិធីទី៤-ពង្រឹងរដ្ឋបាលទូទៅ÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពលើសេវាគាំទ្រទូទៅ ដែលជាកម្មវិធីដើម្បីបង្កើនប្រសិទ្ធភាពដំណើការរដ្ឋបាល និងការទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។ **ឧទាហរណ៍÷** ការពង្រឹងសមត្ថភាពស្ថាប័ន (វគ្គបណ្តុះបណ្តាល, សិក្ខាសាលា, កម្មសិក្សា, ការរៀបចំលិខិតគតិយុត្តិ និងផ្សេងៗ), ការទទួលភ្ញៀវអន្តរជាតិ, ការតាំងពិព័រណ៍, ការឃោសនា និងផ្សព្វផ្សាយ និងផ្សេងៗ។

*បន្ទាប់ពីបង្កើតកម្មវិធីរួច ក្រុមការងារថវិកាត្រូវរៀបចំបង្កើតរចនាសម្ព័ន្ធអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដូចបានបង្ហាញខាងក្រោម។*

### ៣.២.៣ ការបង្កើតអនុកម្មវិធី

ទោះបីជាគោលបំណងគោលនយោបាយមានតែមួយ និងកម្មវិធីមានចំនួន៤ក៏ដោយ ក៏ចំនួនអនុកម្មវិធីមិនមានចំនួនកំណត់ឡើយ។ អនុកម្មវិធីនៅក្រោមកម្មវិធីនីមួយៗ ត្រូវតែឆ្លុះបញ្ចាំងគោលបំណងនៃកម្មវិធី និងត្រូវមានគោលបំណងច្បាស់លាស់ ដើម្បីអាចឱ្យយើងរៀបចំចង្កោមសកម្មភាពបានត្រឹមត្រូវសម្រាប់សម្រេចបានលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី។ ឧទាហរណ៍នៅតារាងទី៣ខាងក្រោមបង្ហាញអំពីរចនាសម្ព័ន្ធអនុកម្មវិធី។

*តារាងទី៣÷ ឧទាហរណ៍ស្តីពីទំនាក់ទំនងរវាងកម្មវិធី និងអនុកម្មវិធី*

| កម្មវិធី | អនុកម្មវិធី |
|---|---|
| **១.អភិវឌ្ឍវិស័យសេដ្ឋកិច្ច** | ១.១ កសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ |
| | ១.២ ពង្រឹងវិស័យកសិកម្ម និងនេសាទ |
| | ១.៣ កែលម្អការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ |

| | |
|---|---|
| | ១.៤ ការអភិវឌ្ឍវិស័យទេសចរណ៍ |
| **២.ពង្រឹងវិស័យសង្គមកិច្ច** | ២.១ កិច្ចគាំពារសង្គមដល់ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ |
| | ២.២ ការលើកកម្ពស់ការថែរក្សាបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងគ្រោះមហន្តរាយ |
| | ២.៣ ការអភិវឌ្ឍការអប់រំ, ជំនាញបច្ចេកទេស និងអប់រំកាយនិងកីឡា |
| | ២.៤ ពង្រឹងស្តង់ដារសុខភាព និងអាហារូបត្ថម្ភ |
| | ២.៥ លើកកម្ពស់ការអភិវឌ្ឍយុវជន និងកីឡា |
| **៣. លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ** | ៣.១ ពង្រឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព |
| | ៣.២ ពង្រឹងការការពារការជួញដូរមនុស្ស |
| | ៣.៣ កាត់បន្ថយការរត់ពន្ធ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ |
| **៤. ពង្រឹងរដ្ឋបាលទូទៅ** | ៤.១ បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល |
| | ៤.២ សេវាគាំទ្រទូទៅ |

## ៣.២.៤ ការបង្កើតចង្កោមសកម្មភាព

ចង្កោមសកម្មភាព គឺជាបណ្តុំសកម្មភាព ដែលមានគោលបំណងច្បាស់លាស់ ឆ្លើយតបទៅនឹងគោលបំណងរបស់អនុកម្មវិធី។ ដូចបានបង្ហាញក្នុងតារាងទី៤ អនុកម្មវិធី៤.១ស្តីពី***«ការបង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល»*** មានចង្កោមសកម្មភាព៤.១.១ ស្តីពី ***«ការពង្រឹងសមត្ថភាពស្ថាប័ន »***។ ដើម្បីសម្រេចលទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាពនេះ ត្រូវមានសកម្មភាពលម្អិតមួយចំនួនដូចជា÷ ការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា, ប្រជុំ និងកម្មសិក្សា ដូចបានបង្ហាញក្នុងតារាងទី៥ខាងក្រោម។ ដូចនេះ ដើម្បីធានាថាចង្កោមសកម្មភាពមានភាពសមស្រប គួរតែធ្វើការចោទសួរនូវសំណួរមួយចំនួនដូចខាងក្រោម÷

- *ភាពសមស្រប (Appropriateness)*
  - ✓ តើចង្កោមសកម្មភាពនឹងបង្កើតលទ្ធផលក្នុងឆ្នាំ តាមការរំពឹងទុកដែរឬទេ?
  - ✓ តើចង្កោមសកម្មភាពមានភាពចាំបាច់សម្រាប់បង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?
  - ✓ តើមានចង្កោមសកម្មភាពណាដែលបង្កើតលទ្ធផលក្នុងឆ្នាំដូចគ្នា?
- *លទ្ធភាពដែលអាចអនុវត្តបាន (Feasibility)*
  - ✓ តើចង្កោមសកម្មភាពអាចអនុវត្តបានតាមលក្ខណៈបច្ចេកទេសដែរឬទេ?
  - ✓ តើមានជម្រើសផ្នែកបច្ចេកទេសដែរឬទេ? ប្រសិនបើមាន តើជម្រើសណាមួយដែលល្អ?

- ✓ តើធនធាន ឬហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ អាចប្រើប្រាស់មានប្រសិទ្ធភាពដែរឬទេ? ជាជាងការទិញសម្ភារបរិក្ខារថ្មី ឬសាងសង់អគារថ្មី?

- ➢ *សមត្ថភាព (Capacity)*
  - ✓ តើមានសមត្ថភាពចាំបាច់គ្រប់គ្រាន់រួចហើយឬនៅសម្រាប់អនុវត្តចង្កោមសកម្មភាព ដើម្បីបង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?
  - ✓ ប្រសិនបើបញ្ហាសមត្ថភាពនៅមានកម្រិតហើយគ្មានធនធានបន្ថែម តើគួរចាត់វិធានការបែបណាដើម្បីកែលម្អសមត្ថភាព ?

- ➢ *លទ្ធផលដែលមិនបានគិតទុកជាមុន (Unintended Results)*
  - ✓ តើមានលទ្ធផលជាអវិជ្ជមាន ( ឧទាហរណ៍ ការធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន) ដែរឬទេ?
  - ✓ ប្រសិនបើមាន តើមានវិធានការអ្វីដើម្បីកាត់បន្ថយលទ្ធផលអវិជ្ជមាននេះដែរឬទេ?

*តារាងទី៤÷ ការរៀបចំចង្កោមសកម្មភាព*

| **ឧទាហរណ៍÷ អនុកម្មវិធី៤.១ស្តីពីការបង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល** | **ចង្កោមសកម្មភាព** |
|---|---|
| | ៤.១.១ ពង្រឹងសមត្ថភាពស្ថាប័ន<br>៤.១.២ រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ<br>៤.១.៣ ចូលរួម ទំនាក់ទំនងផ្សព្វផ្សាយសាធារណៈ |

### ៣.២.៥ ការបង្កើតសកម្មភាព

សកម្មភាពនីមួយៗ ត្រូវតែមានគោលដៅឆ្ពោះទៅសម្រេចគោលបំណងជាក់លាក់ ដែលនឹងរួមចំណែកសម្រេចគោលបំណងនៃចង្កោមសកម្មភាព។ ដើម្បីធានាថា រាល់សកម្មភាពទាំងអស់ត្រូវបានគ្រោងសម្រាប់អនុវត្ត ហើយការចំណាយសម្រាប់អនុវត្តសកម្មភាពទាំងនោះ ដែលនឹងត្រូវបូកសរុបជាការចំណាយរួមរបស់ចង្កោមសកម្មភាព, អនុកម្មវិធី និងកម្មវិធី គួរតែមើលទៅលើប្រភេទទាំង៤នៃសកម្មភាព ដូចខាងក្រោម÷

- ❖ *សកម្មភាពវិនិយោគសាធារណៈ*

ជាទូទៅសកម្មភាពវិនិយោគសាធារណៈ ពាក់ព័ន្ធនឹងការទិញទ្រព្យសកម្មរយៈពេលវែង ដូចជា រថយន្ត សម្ភារបរិក្ខារ ឬ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ និងស្ពាន ការផលិតថាមពលអគ្គិសនី ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធធារាសាស្ត្រ។ល។ សកម្មភាពវិនិយោគមានពាក់ព័ន្ធនឹងថ្លៃចំណាយបច្ចុប្បន្ន ដែលត្រូវធ្វើការ

ពិចារណាចាប់តាំងពីដំបូងមកម្ល៉េះ។ **ឧទាហរណ៍÷** ការសាងសង់ផ្លូវថ្នល់ថ្មី នឹងត្រូវមានការចំណាយថវិកាបន្ថែមសម្រាប់ការថែទាំផ្លូវថ្នល់ ដើម្បីធានាថាផ្លូវថ្នល់ទាំងអស់មានគុណភាពគង់វង្ស ស្របតាមស្តង់ដារគុណភាពដែលតម្រូវ។

❖ ***សកម្មភាពសេវាសង្គមកិច្ច និងបរិស្ថាន***

សកម្មភាពនេះពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំ, សុខាភិបាល និងផ្សេងៗ ដូចជា សកម្មភាពជួយដល់សង្គម (ដូចជា ការទិញអង្ករឧបត្ថម្ភដល់ជនក្រីក្រ), ការឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល និងសកម្មភាពគ្រប់គ្រងការប្រើប្រាស់ដីធ្លី, បរិស្ថាន (កែលម្អសួនសាធារណៈ ការប្រមូលសម្រាម និងការស្តារប្រព័ន្ធប្រឡាយទឹកកខ្វក់), គ្រោះមហន្តរាយ, ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ។

❖ ***សកម្មភាពសន្តិសុខ និងសុវត្ថិភាពសាធារណៈ***

សកម្មភាពនេះ ពាក់ព័ន្ធការធ្វើអន្តរាគមន៍ផ្សេងៗ ដូចជា ការលើកកម្ពស់សុវត្ថិភាពភូមិ ឃុំ, ការទប់ស្កាត់ការជួញដូរមនុស្ស, ការកាត់បន្ថយការរត់ពន្ធ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។

❖ ***សកម្មភាពរដ្ឋបាល***

ជាទូទៅ សកម្មភាពរដ្ឋបាល គឺជាការងារមានលក្ខណៈជាកិច្ចការគ្រប់គ្រង សម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិការប្រចាំថ្ងៃ។ សកម្មភាពទាំងនេះ គឺជាកិច្ចការរដ្ឋបាលទូទៅរបស់ការិយាល័យ ដែលជាសកម្មភាពប្រចាំថ្ងៃ និងមិនងាយនឹងបែងចែកជាឯកតា និងបរិមាណ ដើម្បីងាយស្រួលក្នុងការរៀបចំផែនការ និងការគណនាថ្លៃចំណាយឡើយ។ នៅក្នុងករណីភាគច្រើន បន្ទុកការងារ ឬកិច្ចការដែលអនុវត្តនៅក្នុងរដ្ឋបាល មានទំនាក់ទំនងទៅនឹងរចនាសម្ព័ន្ធរបស់អង្គភាព។ សកម្មភាពរដ្ឋបាល បែងចែកជា០៣ប្រភេទ÷

១. កិច្ចការជាក់លាក់ ដូចជា ការចុះត្រួតពិនិត្យ និងផ្សេងៗ

២. ដំណើរការដែលអនុវត្តប្រចាំថ្ងៃ ដូចជា÷ ការចូលរួមសិក្ខាសាលា, វគ្គសិក្សា និងទំនាក់ទំនងជាមួយនឹងអង្គភាពប្រតិបត្តិការផ្សេងៗ និង

៣. ការថែទាំអគារ និងសម្ភារបរិក្ខារ។

***តារាងទី៥÷ ការរៀបចំសកម្មភាព***

| **ឧទាហរណ៍÷ចង្កោមសកម្មភាពទី៤.១.១ស្តីពីការពង្រឹងសមត្ថភាពស្ថាប័ន** | **សកម្មភាព** |
|---|---|
| | ៤.១.១.១ វគ្គបណ្តុះបណ្តាល<br>៤.១.១.២ សិក្ខាសាលា |

| | |
|---|---|
| | ៤.១.១.៣ ប្រជុំ<br>៤.១.១.៤ កម្មសិក្សា |

**៣.៣ ជំហានទី៣-វិធីសាស្ត្រកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

*(ជំហានទី ៣ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី១.១ ដូចមានជូនភ្ជាប់មកជាមួយ)*

ក្រោយពីបានបង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព ជំហានបន្ទាប់ត្រូវកំណត់ពីគោលបំណងរបស់វា។ ទោះជាយ៉ាងណាក៏ដោយ ពុំចាំបាច់កំណត់ពីគោលបំណងរបស់សកម្មភាពទេ។ ការកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព គឺផ្តើមចេញពីការពិនិត្យទៅលើបញ្ហាប្រឈមដែលត្រូវដោះស្រាយ ហើយទន្ទឹមនោះ យើងក៏ត្រូវយកចិត្តទុកដាក់ផងដែរថា គោលបំណងនោះមានទិសដៅ និងគោលដៅដែលអាចសម្រេចបាន។ ជាឧទាហរណ៍ តារាងទី៦ និង៧ ខាងក្រោមបង្ហាញពីការកំណត់គោលបំណងរបស់កម្មវិធី និងអនុកម្មវិធី។

គួរកត់សំគាល់ថា ការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព គឺត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ច ឬការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត។ ការធ្វើដូចនេះ មិនត្រឹមតែអាចឱ្យយើងអាចធ្វើការកែលម្អការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចជួយឲ្យមានទំនុកចិត្តថា កិច្ចការដែលត្រូវបំពេញអាចសម្រេចបានល្អ និងមានការទទួលខុសត្រូវច្បាស់លាស់លើសមិទ្ធកម្ម។

***តារាងទី៦÷ ឧទាហរណ៍គោលបំណងនៃកម្មវិធី***

| **កម្មវិធី** | **គោលបំណង** |
|---|---|
| **១. អភិវឌ្ឍវិស័យសេដ្ឋកិច្ច** | កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ |
| **២.ពង្រឹងវិស័យសង្គមកិច្ច** | ពង្រឹងសេវាសាធារណៈ និងលើកកម្ពស់វិស័យកីឡា, អប់រំ,សុខាភិបាល, វប្បធម៌ និងផ្សេងៗ។ ឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល។ ធានាចិរភាពបរិស្ថានល្អ, គ្រោះមហន្តរាយ, បម្រែបម្រួលអាកាសធាតុ, ការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ។ |
| **៣.លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ** | គាំទ្រសន្តិសុខសង្គម និងគាំទ្រដំណើរការលុបបំបាត់បទល្មើសផ្សេងៗ |

| | |
|---|---|
| **៤. ពង្រឹងរដ្ឋបាលទូទៅ** | បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល និងការទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ |

***តារាងទី៧÷ ឧទាហរណ៍គោលបំណងនៃអនុកម្មវិធី***

| **ឧទាហរណ៍÷ អនុកម្មវិធី** | **គោលបំណង** |
|---|---|
| **១.១ បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល** | ពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈការបណ្តុះបណ្តាល, សិក្ខាសាលា, កម្មសិក្សា, រៀបចំលិខិតគតិយុត្តិ និងផ្សេងៗ |
| **១.២ សេវាគាំទ្រទូទៅ** | ការទទួលភ្ញៀវអន្តរជាតិ, ការតាំងពិព័រណ៍, ការឃោសនា និងផ្សព្វផ្សាយ និងផ្សេងៗ |

គោលបំណងនៃកម្មវិធី និងអនុកម្មវិធី ដូចបានបង្ហាញជាឧទាហរណ៍ក្នុងតារាងទី៦ និងទី៧ខាងលើ គឺជាសារមួយខ្លី តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលបង្ហាញអំពីគោលបំណង និងប្រាប់ពីមូលហេតុថា ហេតុអ្វីបានជាយើងត្រូវបង្កើតកម្មវិធី និងអនុកម្មវិធី។ ម្យ៉ាងទៀត គោលបំណងនោះត្រូវមានទំនាក់ទំនងទៅនឹងលទ្ធផលចុងក្រោយនៃកម្មវិធី និងលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព។ ដូចនេះ មានន័យថា រាល់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលបានកំណត់ត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងគោលបំណងនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ។

បន្ទាប់ពីការកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរួចហើយ យើងអាចធ្វើការពិនិត្យឡើងវិញអំពីភាពសមស្រប ដោយលើកជាសំណួរមួយចំនួនដូចខាងក្រោម ÷

- ✓ តើកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបង្កើតឡើងមានភាពច្បាស់លាស់ឬទេ ?
- ✓ តើគោលបំណងនៃកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបានឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលឬទេ ?
- ✓ តើយើងអាចបង្កើតសូចនាករសមិទ្ធកម្មគន្លឹះ (KPI) សម្រាប់វាស់វែងគោលបំណងកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបានដែរឬទេ ? (ការធ្វើដូច្នេះ គឺដើម្បីដឹងថានៅពេលណាយើងនឹងសម្រេចបានតាមគោលបំណងនោះ)
- ✓ តើគោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពមានទំនាក់ទំនងនឹងគ្នាឬទេ? ហើយតើគោលបំណងទាំងនេះមានទំនាក់ទំនងទៅនឹងលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំដែរ

ឬទេ? ហើយតើគោលបំណងនៃចង្កោមសកម្មភាពគាំទ្រគោលបំណងនៃអនុកម្មវិធី និងគោលបំណងនៃអនុកម្មវិធីគាំទ្រដល់គោលបំណងនៃកម្មវិធីដែរឬទេ?

## ៣.៤ ជំហានទី ៤- វិធីសាស្ត្រក្នុងការកំណត់ខ្សែសង្វាក់លទ្ធផល

***(ជំហានទី ៤ នេះ បានផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ១.២ និង១.៣ ដូចមានជូនភ្ជាប់មកជាមួយ)***

បន្ទាប់ពីបានរៀបចំរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព និងកំណត់គោល-បំណងរបស់វារួចមក ជំហានបន្ទាប់ គឺការសាងទិន្នន័យសម្រាប់ខ្សែសង្វាក់លទ្ធផល ដែលជា «***ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករសមិទ្ធកម្មនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ***»។ ដ្យាក្រាមទី១ បង្ហាញអំពីដំណើរការពីលើចុះក្រោម/ពីក្រោមឡើងលើនៃខ្សែសង្វាក់លទ្ធផល។ ហើយដ្យាក្រាមទី២ បង្ហាញអំពីឋានានុក្រម និងឡូជីកនៃខ្សែសង្វាក់លទ្ធផលរបស់កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព។ ជារួម សូចនាករ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ (Outcome)គឺសម្រាប់កម្រិតកម្មវិធី រីឯសូចនាករ និងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ (Output) គឺសម្រាប់កម្រិតអនុកម្មវិធី និងចង្កោមសកម្មភាព។

**ដ្យាក្រាមទី១÷ ខ្សែសង្វាក់លទ្ធផល**



ដ្យាក្រាមទី២÷ ឋានានុក្រម និងឡូជីកនៃខ្សែសង្វាក់លទ្ធផល




សម្គាល់÷

-1 KPI/POC ១សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលចុងក្រោយនៃកម្មវិធី (Outcome)

-4 KPIs/SPOP ៤សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី (cost, quantity, quality, time)

-1 KPI/ACOP ១សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាព (operations tracks)

-2 KPIs/AC ២សូចនាករសមិទ្ធកម្មគន្លឹះក្នុង១សកម្មភាព (financial and physical progress)

*តារាងទី ៨: ឧទាហរណ៍ស្តីពីឋានានុក្រមនៃខ្សែសង្វាក់លទ្ធផល*

| ពាក្យ | អត្ថន័យ | ឧទាហរណ៍ |
|---|---|---|
| លទ្ធផលចុងក្រោយ (Outcome) | លទ្ធផលដែលទទួលបានពីការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ | ចំនួនមន្ត្រីដែលបានយកបច្ចេកទេសថ្មីមកអនុវត្ត បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល |
| លទ្ធផលក្នុងឆ្នាំ (Output) | ទំនិញ និងសេវាដែលបានមកពីការអនុវត្តចង្កោមសកម្មភាព និងសកម្មភាព | ចំនួនវគ្គបណ្តុះបណ្តាល, ចំនួនមន្ត្រីដែលទទួលបានការបណ្តុះបណ្តាលវគ្គបច្ចេកទេសថ្មី |
| សកម្មភាព (Activities) | សកម្មភាពដែលមានគោលបំណងច្បាស់លាស់នៅក្នុងចង្កោមសកម្មភាព | ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំ កម្មសិក្សា និងផ្សេងៗ |

### ៣.៤.១ ការកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី

***(ចំណុច ៣.៤.១ មានសារសំខាន់សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី១.៣ ជួរឈរទី ៥)***

នៅពេលកម្មវិធី និងអនុកម្មវិធីបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគោលបំណងគោលនយោបាយជំហានបន្ទាប់ គឺត្រូវកំណត់លទ្ធផលចុងក្រោយ (Outcome) ដែលកម្មវិធីត្រូវបានបង្កើតឡើងដើម្បីសម្រេចឱ្យបាន។ លទ្ធផលចុងក្រោយ (Outcome) ត្រូវកំណត់យ៉ាងណា ដើម្បីអាចវាស់វែងបាន (Measurable Result) និងធានាថាគោលបំណងនៃកម្មវិធីអាចសម្រេចបានតាមការគ្រោងទុក។ កម្មវិធីនីមួយៗ ត្រូវមានលទ្ធផលចុងក្រោយយ៉ាងតិចមួយ។

ការកំណត់លទ្ធផលចុងក្រោយត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម ៖

- ✓ ឆ្លុះបញ្ចាំងពីគោលបំណងច្បាស់លាស់នៃកម្មវិធី
- ✓ ឆ្លុះបញ្ចាំងពីលទ្ធផលដែលកម្មវិធីចង់បាន
- ✓ មានសូចនាករ ដែលអាចធ្វើការតាមដាន និងវាយតម្លៃលទ្ធផលបាន
- ✓ ត្រូវកំណត់ឱ្យបានច្បាស់ចំពោះអ្នកដែលត្រូវទទួលផលពីការអនុវត្តកម្មវិធី និង
- ✓ លទ្ធផលចុងក្រោយ ត្រូវមានការពិគ្រោះយោបល់ឱ្យបានទូលាយ ដើម្បីជៀសវាងការលើកកម្មវិធីត្រួតគ្នា និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបែងចែកមុខងារនិងភារកិច្ចរវាងភាគីពាក់ព័ន្ធ។

**ឧទាហរណ៍ទី១៖** ***កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច*** មានអនុកម្មវិធីស្តីពី ***ការពង្រឹងវិស័យកសិកម្ម និងនេសាទ***។ ការបង្កើនផលិតភាពកសិកម្មតាមរយៈសេវាប្រពលវប្បកម្មកាន់តែរឹងមាំ និងលំហូរនៃបច្ចេកវិទ្យាដាំដុះ

ថ្មីអាចជួយជំរុញកំណើនវិស័យកសិកម្ម និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ព្រោះវាបានលើកទឹកចិត្តដល់ប្រជាកសិករ ដែលមានស្រាប់នៅក្នុងវិស័យនេះឱ្យបង្កើនផលិតភាព និងជំរុញឱ្យមានវិនិយោគិនថ្មីបើកអាជីវកម្មកសិធុរកិច្ច បង្កើតការងារ បង្កើនប្រាក់ចំណូល និងបង្កើនការប្រមូលពន្ធ។

ជាទូទៅ ផលវិបាកក្នុងការកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី គឺការធានាថាលទ្ធផលចុងក្រោយអាចវាស់វែងបាន និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។ ការបង្កើនផលិតភាពកសិកម្មដែលបានបង្ហាញខាងលើ អាចសម្រេចគោលបំណងនៃលទ្ធផលចុងក្រោយ និងអាចវាស់វែងផលិតភាពកសិកម្មបាន។ ប៉ុន្តែលទ្ធផល ដែលអាចមានផ្សេងទៀត គឺហួសពីសមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ជាពិសេសការលើកទឹកចិត្តឱ្យមានវិនិយោគិនថ្មីចាប់ផ្តើមបើកអាជីវកម្មកសិធុរកិច្ច ដែលនឹងបង្កើតការងារ បង្កើនប្រាក់ចំណូល និងបង្កើនការប្រមូលពន្ធ។ អាស្រ័យហេតុនេះ ពេលកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី ចាំបាច់ត្រូវធានាថាលទ្ធផលចុងក្រោយ គឺស្ថិតនៅក្នុងវិសាលភាពនៃការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តក្នុងគោលបំណងធានាគណនេយ្យភាពសម្រាប់សមិទ្ធកម្ម។ ទោះជាយ៉ាងណាក៏ដោយ អាកាសធាតុមិនអំណោយផល ដែលមិនអាចប៉ាន់ស្មានដឹងមុន និងឥរិយាបថផ្លាស់ប្តូររបស់កសិករ ក៏អាចប៉ះពាល់ដល់ការសម្រេចលើកម្មវិធីផងដែរ។

***ឧទាហរណ៍ទី២÷ ការបញ្ចប់ការសាងសង់ផ្លូវថ្មី គឺជាលទ្ធផលសម្រេចបាន។*** អត្ថប្រយោជន៍ទទួលបានពីផ្លូវនេះ គឺការរួមចំណែកដល់ការកាត់បន្ថយថ្លៃចំណាយលើការថែទាំរថយន្ត, កាត់បន្ថយពេលវេលាធ្វើដំណើរ ដែលធ្វើឱ្យកសិករងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលទៅទីផ្សារ ដែលនេះជាការរួមចំណែករបស់វិស័យកសិកម្មដល់កំណើនសេដ្ឋកិច្ច។ ក្រៅពីនេះ អត្ថប្រយោជន៍ពីវិស័យកសិកម្មក៏ពឹងផ្អែកយ៉ាងខ្លាំងទៅលើកត្តាផ្សេងទៀត មានដូចជា÷ ផលិតភាពកសិកម្ម, គ្រាប់ពូជ និងអាកាសធាតុ។ ទោះជាយ៉ាងនេះក្តី ការសិក្សាលើកត្តាទាំងនេះមានការលំបាកខ្លាំងដោយសារត្រូវចំណាយធនធានច្រើន និងមិនអាចធ្វើការវាយតម្លៃបានញឹកញាប់ និងជាទៀងរាល់ប្រាំឆ្នាំឡើយ។

ដូចនេះ ដើម្បីសម្រេចគោលបំណងនៃលទ្ធផលចុងក្រោយ (Outcome) ចាំបាច់ត្រូវធានាថា ការកំណត់លទ្ធផលចុងក្រោយមានភាពប្រាកដប្រជា ដើម្បីអាចឱ្យកម្មវិធីនេះរួមចំណែកដល់ការសម្រេចនូវគោលបំណងគោលនយោបាយ។ ផ្អែកលើឧទាហរណ៍ខាងលើ លទ្ធផលចុងក្រោយ (Outcome) ដែលរួមមាន÷

- ✓ ការបង្កើនការរួមចំណែករបស់វិស័យកសិកម្មរបស់រដ្ឋបាលខេត្តនៅក្នុងផ.ស.ស
- ✓ ការកាត់បន្ថយម៉ោងធ្វើដំណើរ និង
- ✓ ការកាត់បន្ថយថ្លៃចំណាយលើការថែទាំរថយន្ត។

ទោះបីជាកម្មវិធីមានលទ្ធផលចុងក្រោយចំនួនបីយ៉ាងណាក៏ដោយ ក៏មានលទ្ធផលមួយដែលរដ្ឋបាលរាជធានី ខេត្តមានលទ្ធភាពងាយស្រួលក្នុងការវាស់វែង គឺ« ***ការកាត់បន្ថយពេលវេលាធ្វើដំណើរ*** »។

### ៣.៤.២ ការកំណត់លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព

*(ចំណុច ៣.៤.២ នេះមានសារសំខាន់សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី១.២ ជួរឈរទី២ និងតារាងទី១.៣ ជួរឈរទី៣)*

លទ្ធផលក្នុងឆ្នាំ (Output) គឺជាលទ្ធផលអាចវាស់បានក្នុងឆ្នាំ ដែលអាចឈានទៅសម្រេចបានលទ្ធផលចុងក្រោយ និងឈានទៅសម្រេចគោលបំណងនៃកម្មវិធីដែលចង់បាន។ លទ្ធផលក្នុងឆ្នាំ (Output) គឺសំដៅដល់សេវា និងទំនិញ ដូចជា ផ្លូវ សួនច្បារ អគារ លូ ។ល។ ដែលទទួលបានពីសកម្មភាព ឬដំណើរការអ្វីមួយ។ លទ្ធផលក្នុងឆ្នាំ (Output) មានពីរកម្រិតគឺ កម្រិតអនុកម្មវិធី និងចង្កោមសកម្មភាព។ ដូចនេះ ការសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី នឹងឈានទៅសម្រេចបានលទ្ធផលចុងក្រោយ (Outcome)នៃកម្មវិធី និងគោលបំណងគោលនយោបាយ (Policy Objective)។ ចំណែក ការសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output) នៃចង្កោមសកម្មភាព នឹងឈានទៅសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី និងលទ្ធផលចុងក្រោយ (Outcome)នៃកម្មវិធី។

**ឧទាហរណ៍÷** នៅក្នុងដំណើរការកសាងផ្លូវថ្នល់ មានសកម្មភាព ដូចជា ការប្រមូលកាកសំណល់រឹង ការថែទាំសួនច្បារសាធារណៈ ការដាក់ភ្លើងបំភ្លឺផ្លូវ ការពង្រឹងសុវត្ថិភាពផ្លូវថ្នល់ និងផ្សេងៗ ដើម្បីសម្រេចលទ្ធផលចុងក្រោយនៃកម្មវិធីគឺ ***«ផ្លូវថ្នល់»***។

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតលទ្ធផលក្នុងឆ្នាំ (Output)របស់ខ្លួន ដោយធ្វើការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ។ ដោយសារលទ្ធផលក្នុងឆ្នាំទាំងអស់ត្រូវរួមចំណែកដល់ការបង្កើតលទ្ធផលចុងក្រោយជាក់លាក់ណាមួយ ដើម្បីសម្រេចបានគោលបំណងរបស់កម្មវិធី ដូច្នេះ ការកំណត់លទ្ធផលក្នុងឆ្នាំ (Output) ត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម÷

- ✓ ត្រូវស្ថិតនៅក្នុងវិសាលភាពគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ទោះជាការអនុវត្តដោយផ្ទាល់ ឬជាកិច្ចសន្យាជាមួយនឹងភាគីខាងក្រៅក៏ដោយ
- ✓ ចំនួនអ្នកដែលត្រូវទទួលផលពីការផ្តល់ទំនិញ និងសេវា
- ✓ ត្រូវតែអាចវាស់វែងបាន ពាក់ព័ន្ធនឹងថ្លៃ***ចំណាយ, បរិមាណ, គុណភាព និងពេលវេលា***
- ✓ ត្រូវមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីងាយស្រួលកំណត់អ្នកទទួលខុសត្រូវ និងគ្រប់គ្រង
- ✓ ត្រូវមានភាពច្បាស់លាស់អំពីថវិកា ដែលត្រូវចំណាយ និងលទ្ធផលទទួលមកវិញ។

### ៣.៥ ជំហានទី ៥- ពិនិត្យឡើងវិញលើឡូជីក (Logic) នៃការកសាងរចនាសម្ព័ន្ធកម្មវិធី

*(ជំហានទី ៥ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី ១.១, ១.២ និង១.៣ ដូចមានជូនភ្ជាប់មកជាមួយ)*

ជាក់ស្តែងការកសាងថវិកាកម្មវិធី គឺជាដំណើរការមួយដែលទាមទារនូវការពិនិត្យសារចុះសារឡើង ដើម្បីធានាសង្គតិភាពនៃការរៀបចំកម្មវិធី ជាពិសេស ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយដែលបានដាក់ចេញ។ រចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលបានរៀបចំរួច តម្រូវឱ្យក្រុមការងារថវិកាត្រូវពិនិត្យសារចុះសារឡើង ដើម្បីធ្វើយ៉ាងណាឱ្យមានលក្ខណៈសម្បត្តិដូចខាងក្រោម÷

- ✓ ត្រូវរំលេចឱ្យឃើញអំពីគោលដៅចំបងៗរបស់រដ្ឋបាលរាជធានី ខេត្ត។ ដោយផ្អែកលើគោលដៅដែលបានកំណត់ រដ្ឋបាលរាជធានី ខេត្តត្រូវបង្កើតរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដើម្បីអាចធានាបាននូវគណនេយ្យភាពច្បាស់លាស់។
- ✓ ត្រូវមានការគិតគូជាចំបងលើគោលនយោបាយ និងវិស័យអាទិភាពថ្មីៗដែលរាជរដ្ឋាភិបាលបានដាក់ចេញ (ប្រសិនបើមាន) ដើម្បីរក្សានូវសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា ដែលបានរៀបចំ និងជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំថ្នាក់ក្រោមជាតិ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ក្រោមជាតិ។
- ✓ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចមានវិស័យអាទិភាព ដែលត្រូវអនុវត្តខុសៗគ្នា ទោះបីជាត្រូវមានគោលបំណងគោលនយោបាយចំនួនមួយ (១) និងកម្មវិធីចំនួនបួន (៤)ក៏ដោយ ក៏រដ្ឋបាលរាជធានីខេត្តនីមួយៗនៅតែអាចរៀបចំរចនាសម្ព័ន្ធអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពឱ្យស្របទៅតាមវិស័យអាទិភាពរៀងៗខ្លួន។
- ✓ រចនាសម្ព័ន្ធកម្មវិធី រួមមានកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ✓ ចំពោះឈ្មោះនៃអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ត្រូវមានលក្ខណៈជាការពិពណ៌នា (Descriptive) ពីបញ្ហាចង់ដោះស្រាយ។ រីឯគោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពត្រូវមានលក្ខណៈច្បាស់លាស់ ព្រោះត្រូវឆ្លើយតបទៅនឹងបេសកកម្ម និងគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.៦ ជំហានទី៦- ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI)

***(ជំហានទី ៦ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីអាចបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ១.២ និង ១.៣ ដូចមានភ្ជាប់ជូនមកជាមួយ)***

ដើម្បីបង្កើតរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងលទ្ធផលចុងក្រោយ (Outcome) និងលទ្ធផលក្នុងឆ្នាំ (Output)បាន គឺចាំបាច់បំផុតត្រូវកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) និងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះ (KPI Target) ដើម្បីឱ្យសមិទ្ធកម្មដែលបានគ្រោងទុកអាចវាស់វែងបាន ដោយធៀបជាមួយនឹងសមិទ្ធកម្មជាក់ស្តែង ដូចមានបង្ហាញក្នុងតារាងទី៩ខាងក្រោម។

❖ ***ឋានានុក្រមនៃសូចនាករសមិទ្ធកម្មគន្លឹះ***

សម្រាប់ការរៀបចំថវិកាកម្មវិធី ពុំចាំបាច់កំណត់ KPI សម្រាប់គោលបំណងគោលនយោបាយនោះទេ ដោយសារតែគោលបំណងគោលនយោបាយត្រូវតែកំណត់ និងវាស់វែងនៅថ្នាក់ជាតិ។ ការរៀបចំថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវតែកំណត់ KPI សម្រាប់លទ្ធផលចុងក្រោយនៃកម្មវិធី, លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព និងសម្រាប់សកម្មភាព។ ឋានានុក្រមនៃសូចនាករសមិទ្ធកម្មគន្លឹះ(KPI)បានបង្ហាញក្នុងតារាងទី៩ខាងក្រោម÷

***តារាងទី៩÷ ឋានានុក្រមសូចនាករសមិទ្ធកម្មគន្លឹះ***

| គោលដៅ | ចំនួនសូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|
| -លទ្ធផលចុងក្រោយនៃកម្មវិធី | KPI មួយ (១) ដែលត្រូវវាស់វែងសមិទ្ធកម្ម (Performance) |
| -លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី | KPI បួន (៤) ដែលត្រូវវាស់វែងបរិមាណ (Quantity), គុណភាព (Quality), ពេលវេលា (Time) និងថ្លៃចំណាយ (Cost) |
| -លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាព | KPI មួយ (១) ដែលត្រូវវាស់វែងវឌ្ឍនភាពនៃការអនុវត្ត (Operations Tracks) |
| -សកម្មភាព | KPI ពីរ (២) ដែលត្រូវវាស់វែងវឌ្ឍនភាពជារូបវន្ត (Physical) និងជាហិរញ្ញវត្ថុ (Finance) |

❖ ***ចរិតលក្ខណៈនៃសូចនាករសមិទ្ធកម្មគន្លឹះ***

សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវមានលក្ខណៈ SMART (ច្បាស់លាស់, វាស់វែងបាន, អាចសម្រេចបាន, ពាក់ព័ន្ធ និងពេលវេលាកំណត់) ដូចអត្ថន័យខាងក្រោម÷

- ✓ **ច្បាស់លាស់ (Specific)**÷ ធានាថាលទ្ធផលសម្រាប់ដោះស្រាយបញ្ហាប្រឈមមានការទទួលខុសត្រូវ មានអ្នកទទួលផលប្រយោជន៍ និងនិរន្តរភាពបន្ទាប់ពីបញ្ចប់។
- ✓ **វាស់វែងបាន (Measurable)**÷ មានលទ្ធភាពអាចវាស់វែងបាន, មានព័ត៌មាន និងទិន្នន័យដែលត្រូវការ។
- ✓ **អាចសម្រេចបាន (Attainable)**÷ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចលទ្ធផលចុងក្រោយទៅតាមធនធាន, ពេលវេលា និងគុណភាព។
- ✓ **ពាក់ព័ន្ធ (Relevant)**÷ អាចរៀបចំផែនការប្រតិបត្តិ ផែនការថវិកា និងសកម្មភាពលម្អិត។
- ✓ **ពេលវេលាកំណត់ (Timeframe)**÷ មានពេលវេលាចាប់ផ្ដើម និងបញ្ចប់ច្បាស់លាស់។

សូចនាករសមិទ្ធកម្មគន្លឹះ (KPI) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់គោលដៅសម្រាប់ការវាស់វែង (បរិមាណ) ឬការវិនិច្ឆ័យ (គុណភាព) នូវលទ្ធផលដែលសម្រេចបាន។ សូចនាករមានចំនួនកាន់តែតិច គឺកាន់តែល្អ ពីព្រោះការវាស់វែងការប្រែប្រួល (រួមទាំង ការប្រមូល និងការវិភាគទិន្នន័យ) ត្រូវការចំណាយពេលវេលា និងថវិកា។ ទោះជាយ៉ាងនេះក្ដី ចាំបាច់ត្រូវតែមានសូចនាករគ្រប់ចំនួន ដើម្បីវាស់វែងកម្រិតផ្លាស់ប្ដូរ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី៩ខាងលើ មានសូចនាករសមិទ្ធកម្មគន្លឹះចំនួន៨សម្រាប់វាស់វែង ដូចជានៅកម្រិតលទ្ធផលចុងក្រោយនៃកម្មវិធីចំនួន១ (លទ្ធផលឬសមិទ្ធកម្ម), លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធីចំនួន៤ (បរិមាណ,គុណភាព, ពេលវេលា និងថ្លៃចំណាយ), លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាពចំនួន១ (វឌ្ឍនភាពនៃការអនុវត្ត ដែលសំដៅដល់សេវាត្រូវបានផ្ដល់តាមការគ្រោងទុក) និងនៅកម្រិតសកម្មភាពចំនួន២ (វឌ្ឍនភាពជារូបវន្ត និងជាហិរញ្ញវត្ថុ)។

❖ ***សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលចុងក្រោយ***

***(ចំណុចនេះផ្ដល់នូវគំនិត និង សេចក្ដីពន្យល់ ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ១.៣ ជួរឈរទី ៥)***

សូចនាករលទ្ធផលចុងក្រោយ (Outcome) គឺជារង្វាស់ ដែលអាចកំណត់គោលដៅសមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធីក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ដូចបានបង្ហាញក្នុងតារាងទី១០ លទ្ធផលចុងក្រោយនៃកម្មវិធី ត្រូវបានវាស់វែងដោយ KPI លើសមិទ្ធកម្ម (Performance) ដែលសម្រេចបាន។

**ឧទាហរណ៍**÷ សូចនាករទាំងនេះ រួមមាន÷

- ✓ សិស្សបញ្ចប់ការសិក្សាកាន់តែមានគុណភាពល្អប្រសើរ
- ✓ ការកើនឡើងផលិតភាពកសិកម្ម

✓ ការថយចុះអត្រាមរណភាពដោយសារតែជំងឺឆ្លង និង

✓ ការកើនឡើងលទ្ធភាពទទួលបានទឹកស្អាតបរិភោគ។

ដើម្បីសម្រេចបានសូចនាករលទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី ត្រូវមានការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ (Output) នៃអនុកម្មវិធីមួយចំនួន។ តារាងទី១០ ខាងក្រោមបង្ហាញអំពីការកំណត់សូចនាករលទ្ធផលចុងក្រោយនៃកម្មវិធីទាំងបួនដូចខាងក្រោម។

*តារាងទី១០÷ ឧទាហរណ៍ការកំណត់សូចនាករលទ្ធផលចុងក្រោយ (Outcome)*

| **កម្មវិធី** | **សូចនាករលទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី** | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
|---|---|---|
| **កម្មវិធីទី១-** អភិវឌ្ឍវិស័យសេដ្ឋកិច្ច | ប្រជាជនដែលមានជីវភាពប្រសើរជាងមុន | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី២-** ពង្រឹងវិស័យសង្គមកិច្ច | សេវាសាធារណៈដែលបានផ្តល់ដល់ប្រជាជនត្រូវបានលើកកម្ពស់ និងមានប្រសិទ្ធភាពជាងមុន | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី៣-** លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ | ប្រជាជនរស់នៅក្នុងមូលដ្ឋានដែលមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប្រសើរ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី៤-** ពង្រឹងរដ្ឋបាលទូទៅ | អភិបាលកិច្ចល្អ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |

❖ ***សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំ***

***(ចំណុចនេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ១.២ ជួរឈរទី ២,៣,៤,៥, និង៦ និងតារាងឧបសម្ព័ន្ធទី១.៣ ជួរឈរទី៣ និង៤។)***

**សូចនាករលទ្ធផលក្នុងឆ្នាំ (Output)** គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មនៃការអនុវត្តក្នុងរយៈពេលជាក់លាក់មួយ (មិនលើសពីមួយឆ្នាំ)។

**ឧទាហរណ៍÷**

- ចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាលជំនាញថ្មី
- ចំនួនផ្លូវ ឬ លូទឹក ដែលបានសាងសង់ទៅតាមស្តង់ដារ និង គុណភាព
- ចំនួនអ្នកប្រជាជនដែលទទួលផ្លូវ ឬ សួនច្បារសាធារណៈ

តារាងទី១១ ខាងក្រោមជាឧទាហរណ៍បង្ហាញពីសូចនាករលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធីមួយចំនួន។

***តារាងទី១១÷ ឧទាហរណ៍ការកំណត់សូចនាករលទ្ធផលក្នុងឆ្នាំ***

| **កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព** | **សូចនាករលទ្ធផលក្នុងឆ្នាំ** (Output) | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
|---|---|---|
| **កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច** | | |
| **អនុកម្មវិធីទី១.១-** កសាង និង ថែទាំហេដ្ឋារចនាសម្ព័ន្ធ | **សូចនាករទី ១ :** ប្រវែងផ្លូវប្រភេទ DBST និង AC ដែលបានសាងសង់រួច | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី២:** ប្រវែងផ្លូវប្រភេទ AC ដែលបានជួសជុលរួច | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី ៣:** ប្រវែងប្រព័ន្ធលូតាមផ្លូវក្នុងក្រុង | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី ៤** ផ្ទៃក្រឡាសួនសាធារណៈដែលបានសាងសង់ ឬកែលម្អ | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| **អនុកម្មវិធីទី១.២-** ពង្រឹងវិស័យកសិកម្ម និងនេសាទ | **សូចនាករទី១:** ប្រវែងប្រឡាយដែលបានសាងសង់ | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី២:** ប្រវែងប្រឡាយដែលបានជួសជុល | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |

នៅក្នុងការរៀបចំថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ មាន០២(ពីរ)កម្រិត គឺអនុកម្មវិធី និងចង្កោមសកម្មភាព ដូចខាងក្រោម÷

✓ ***ទី១-សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំសម្រាប់អនុកម្មវិធី***

សូចនាករសមិទ្ធកម្មគន្លឹះ (KIP) សម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី មានចំនួន ០៤ គឺបរិមាណ, គុណភាព,ពេលវេលាកំណត់ និងថ្លៃចំណាយ។

**ឧទាហរណ៍៖** សូចនាករវាស់វែងអនុកម្មវិធីស្តីពីការដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវ ដូចខាងក្រោម៖

- ✓ ចំនួន (បរិមាណ)បង្គោលភ្លើងបំភ្លឺផ្លូវដែលបានដំឡើងរួច
- ✓ គុណភាព (%)នៃបង្គោលភ្លើងបំភ្លឺផ្លូវដែលបានដំឡើងរួច និងបានត្រួតពិនិត្យរួច
- ✓ ពេលវេលា (%)នៃបង្គោលភ្លើងតាមដងផ្លូវដែលបានដំឡើងតាមផែនការ
- ✓ ភាគរយ (%) នៃថវិកាដែលបានចំណាយ

ដូចបានបង្ហាញជាឧទាហរណ៍ក្នុងតារាងទី១២ខាងក្រោម ការប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ដើម្បីវាស់វែងការប្រែប្រួលរវាងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះ (KPI Target) (សមិទ្ធកម្មដែលបានគ្រោង) និងសមិទ្ធកម្មជាក់ស្តែង។ ការប្រើប្រាស់វិធីសាស្រ្តវិភាគលើការប្រែប្រួលនេះ បានផ្តល់ជាមូលដ្ឋានសម្រាប់ជាអនុសាសន៍ក្នុងការផ្តល់ថវិកា ដែលជាមូលដ្ឋានសម្រាប់ការប្រើប្រាស់ថវិកាព័ត៌មានសមិទ្ធកម្មនាពេលអនាគត។

***តារាងទី១២- ឧទាហរណ៍លទ្ធផលក្នុងឆ្នាំ (Output)-ការដំឡើងអំពូលភ្លើងបំភ្លឺផ្លូវថ្នល់ក្នុងភូមិ***

| **សូចនាករសមិទ្ធកម្មគន្លឹះ** | **គោលដៅ សូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០២០** | **សមិទ្ធកម្មជាក់ស្តែងឆ្នាំ២០២០** | **ការប្រែប្រួល%** |
|---|---|---|---|
| *បរិមាណ*<br>ចំនួនអ្នកទទួលផលសរុប | ១២៥០ | ៩៥៦ | -២៣% |
| *គុណភាព*<br>បង្គោលភ្លើងសម្រាប់បំពាក់អំពូលបំភ្លឺផ្លូវថ្នល់ថ្មីដែលបានដាក់ពិន្ទុថាពេញចិត្តដោយអធិការកិច្ច | ១២០ | ៩៨ | -១៨% |
| *ពេលវេលាកំណត់*<br>បង្គោលភ្លើងសម្រាប់បំពាក់អំពូលបំភ្លឺផ្លូវថ្នល់ថ្មីដែលបានដំឡើងដោយស្របតាមកាលវិភាគអនុវត្តដែលបានកំណត់ជាមុន | ១២០ | ៩៨ | -១៨% |

| **សូចនាករសមិទ្ធកម្មគន្លឹះ** | **គោលដៅ សូចនាករសមិទ្ធកម្ម គន្លឹះឆ្នាំ២០២០** | **សមិទ្ធកម្ម ជាក់ស្តែង ឆ្នាំ២០២០** | **ការប្រែប្រួល%** |
|---|---|---|---|
| *ថ្លៃចំណាយ*<br>ថ្លៃចំណាយសរុបលើលទ្ធផលក្នុងឆ្នាំគិតជាលានរៀល | ៥,៨៥០ | ៤,៦៩២ | -១៩% |

*ការវាស់វែងលទ្ធផលក្នុងឆ្នាំ៖*

១. លទ្ធផលក្នុងឆ្នាំបង្ហាញសមិទ្ធកម្មអ្នកទទួលផលពីការផ្គត់ផ្គង់ថាមពលបំភ្លឺផ្លូវថ្នល់ ទោះបីជាចំនួនអ្នកទទួលផលជាក់ស្តែងមានចំនួនតិចជាងគោលដៅក៏ដោយ។

២. ទាំងសូចនាករគុណភាព និងសូចនាករបរិមាណជាក់ស្តែង គឺទាបជាងគោលដៅ។ ការដំឡើងបង្គោលភ្លើងមានការយឺតយ៉ាវជាងកាលកំណត់ ដោយសារតែបញ្ហាអាកាសធាតុដែលធ្វើឱ្យរំខានដល់ការដំឡើង ដែលជាហេតុធ្វើឱ្យមិនអាចសម្រេចគោលដៅជាបរិមាណបាន និងនាំឱ្យប៉ះពាល់ដល់គោលដៅជាគុណភាពផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការដំឡើងបង្គោលភ្លើងត្រូវបានដាក់ពិន្ទុដោយក្រុមអធិការកិច្ចថាពេញចិត្ត។

៣. ដោយសារតែបង្គោលភ្លើង ដែលបានដំឡើងមានចំនួនតិចជាងការគ្រោងទុក ទើបថវិកាមិនត្រូវបានចំណាយទាំងអស់នោះទេ។

៤. ជាសរុប លទ្ធផលគឺល្អ ហើយប្រសិនបើមិនមានបញ្ហាអាកាសធាតុទេ នោះគោលដៅទាំងអស់ប្រហែលជាអាចសម្រេចបានទាន់ពេលវេលាកំណត់។

*អនុសាសន៍៖*

ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាចំណុចអាទិភាពគោលនយោបាយដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ការដំឡើងភ្លើងបំភ្លឺផ្លូវនៅក្នុងភូមិ គឺស្របជាមួយនឹងគោលបំណងគោលនយោបាយ ពីព្រោះវារួមចំណែកដល់ការទប់ស្កាត់បទល្មើស ក៏ដូចជាសុវត្ថិភាពចរាចរណ៍ ផ្លូវគោក និងសុវត្ថិភាពអ្នកថ្មើរជើង។ ជាអនុសាសន៍ ការប្រើប្រាស់ថវិកាសម្រាប់សម្រេចលទ្ធផលក្នុងឆ្នាំនេះ គួរតែបន្តអនុវត្ត និងគួរធ្វើការកែលម្អ ដោយរំពឹងថានឹងបង្កើនថវិកាបន្ថែមទៀតនៅក្នុងឆ្នាំថវិកាបន្ទាប់។

✓ ***ទី២- សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំសម្រាប់ចង្កោមសកម្មភាព***

សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ (Output)នៃចង្កោមសកម្មភាព គឺការតាមដានអំពីវឌ្ឍនភាពនៃការអនុវត្ត (សំដៅដល់សេវាត្រូវបានផ្ដល់តាមការគ្រោងទុក)។

❖ ***សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់សកម្មភាព***

សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់សកម្មភាពមានចំនួន ០២(ពីរ) គឺ÷ ការវាស់វែងវឌ្ឍនភាពជារូបវ័ន្ត និងជាហិរញ្ញវត្ថុ។ ការវាស់វែងសូចនាករសមិទ្ធកម្មទាំងពីរនេះ គឺត្រូវផ្អែកលើរបាយការណ៍ប្រចាំខែ និងការវិភាគលើការប្រែប្រួល ដូចមានបង្ហាញក្នុងតារាងទី១៣ខាងក្រោម។

***តារាងទី១៣- ឧទាហរណ៍ការវិភាគការប្រែប្រួលនៃវឌ្ឍនភាពរូបវ័ន្តសម្រាប់សកម្មភាព***

| **កូដកម្មវិធី (១)** | **សេចក្ដីពណ៌នាសកម្មភាព (២)** | **សូចនាករសកម្មភាព (៣)** | **គោលដៅ (៤)** | **សម្រេចជាក់ស្ដែង (៥)** | **ការប្រែប្រួល (៤-៥) =(៦)** | **% ៦/៤= (៧)** |
|---|---|---|---|---|---|---|
| | សេវាប្រពលវប្បកម្មកសិកម្ម | ចំនួនវគ្គបណ្ដុះបណ្ដាលសម្រាប់កសិករ | ១៥០ | ៥០ | ១០០ | ៦៧% |

ការវិភាគការប្រែប្រួលប្រហាក់ប្រហែលគ្នានេះត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃវឌ្ឍនភាពហិរញ្ញវត្ថុ ដូចបានបង្ហាញក្នុងតារាងទី១៤ ខាងក្រោម។

***តារាងទី១៤÷ ឧទាហរណ៍ការវិភាគការប្រែប្រួលនៃវឌ្ឍនភាពហិរញ្ញវត្ថុសម្រាប់សកម្មភាព***

គិតជាលានរៀល

| **កូដកម្មវិធី (១)** | **សេចក្ដីពណ៌នាសកម្មភាព (២)** | **សូចនាករសកម្មភាព (៣)** | **ចំនួនថវិកា (៤)** | **ថ្លៃចំណាយជាក់ស្ដែង (៥)** | **ការប្រែប្រួល (៤-៥) = (៦)** | **% (៦/៤) = (៧)** |
|---|---|---|---|---|---|---|
| | សេវាប្រពលវប្បកម្មកសិកម្ម | ចំនួនវគ្គបណ្ដុះបណ្ដាលសម្រាប់កសិករ | ២ ៥០០ | ៣ ០០០ | (៥០០) | (១២%) |

តារាងទី១៣ និង ១៤ ខាងលើនេះបង្ហាញថា សកម្មភាពស្តីពី *«ការរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់កសិករ»* ដោយបានកំណត់គោលដៅ និងលទ្ធផលជាក់ស្តែងនៃចំនួនសិក្ខាកាមត្រូវបណ្តុះបណ្តាល (តារាងទី១៣) និងថវិកាត្រូវចំណាយ (តារាងទី១៤)។ សកម្មភាពទាំងអស់ដែលត្រូវការជាចាំបាច់ដើម្បីអនុវត្ត ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ និងគណនាថ្លៃចំណាយឱ្យបានច្បាស់លាស់ បើមិនដូច្នោះទេ នឹងមានបញ្ហាប្រឈមថវិកាមិនគ្រប់គ្រាន់ ដូចបានបង្ហាញក្នុងតារាងទី១៤។

### ៣.៧ ជំហានទី៧- វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី

***(ជំហានទី៧ នេះផ្តល់គំនិត និងវិធីគណនាតម្រូវការ ដើម្បីបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី១.៤, ១.៥,១.៦, ១.៧ និង ១.៨ ដូចមានភ្ជាប់មកជាមួយ)***

ជំហានទី៦ស្តីពីការកំណត់ KPI និងជំហានទី៧ស្តីពីការគណនាតម្រូវការចំណាយ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ព្រោះថាសូចនាករអាចសម្រេចទៅបានអាស្រ័យលើកញ្ចប់ធនធានដែលមាន។ ជាទូទៅ រដ្ឋបាលរាជធានី ខេត្ត អាចជ្រើសរើសការគណនាតម្រូវការចំណាយមុនការកំណត់សូចនាករក៏បានដែរ។ ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំនេះ មានគោលបំណងផ្សារភ្ជាប់ការកំណត់ KPI ទៅនឹងការគណនាតម្រូវការចំណាយ ដើម្បីងាយស្រួលក្នុងការកសាងកម្មវិធី ព្រោះថានៅពេលកសាងថវិកាកម្មវិធីយើងត្រូវពិនិត្យសារចុះសារឡើង ដើម្បីធ្វើយ៉ាងណាឱ្យការកសាងថវិកាតាមកម្មវិធីដែលបានកំណត់នោះអាចអនុវត្តបាននៅក្នុងកម្រិតថវិកាប្រចាំឆ្នាំ និងក្នុងកម្រិតនៃកំណើនថវិកាសម្រាប់រយៈពេល២ឆ្នាំបន្ទាប់។ ផ្នែកនេះ ផ្តល់ការណែនាំអំពីការគណនាតម្រូវការចំណាយ ដែលត្រូវការសម្រាប់អនុវត្តសកម្មភាពការងារត្រូវបានកំណត់។

***ក្នុងការគណនាតម្រូវការចំណាយ រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្អែកលើមូលដ្ឋានគណនាចំនួនពីរគឺ ទី១-ការគណនាតម្រូវការចំណាយដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងទី២-ការគណនាតម្រូវការចំណាយដោយផ្អែកតាមកម្មវិធី។***

ដើម្បីឱ្យកម្មវិធីមួយមានធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្ត និងអាចត្រួតពិនិត្យបានធៀបនឹងកម្មវិធីផ្សេងៗទៀតក្នុងរដ្ឋបាលតែមួយ តម្រូវឱ្យមានយន្តការសម្របសម្រួលមួយសម្រាប់កំណត់តម្រូវការចំណាយនៃកម្មវិធីទាំងនោះ។ ការធ្វើបែបនេះ នឹងជួយពង្រឹងការផ្សារភ្ជាប់តម្រូវការចំណាយថវិកាទៅនឹងលទ្ធផលសម្រេចបាន ព្រមទាំងអាចវាយតម្លៃពីប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់កម្មវិធី។

ជាទស្សនៈ ការចំណាយទាំងអស់ត្រូវវិភាជន៍ទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ធនធានមួយអាចប្រើសម្រាប់កម្មវិធីលើសពីមួយ ដែលយើងគួរបែងចែកទៅតាមភាគរយនៃការប្រើប្រាស់សម្រាប់កម្មវិធីនីមួយៗ។ **ឧទាហរណ៍៖** យានយន្តមួយត្រូវបានប្រើប្រាស់ ៧៥% សម្រាប់

កម្មវិធីទី១ ហើយ២៥%ទៀតសម្រាប់កម្មវិធីទី២។ ដូច្នេះ ៧៥%នៃចំណាយក្នុងការប្រើប្រាស់យានយន្តនេះត្រូវបែងចែកទៅកម្មវិធីទីមួយ និង២៥% ទៀតត្រូវបែងចែកទៅកម្មវិធីទីពីរ។

ផ្ទុយមកវិញ ទោះបីជាការចំណាយគួរតែត្រូវបែងចែកទៅតាមកម្មវិធីប្រសិនបើអាចធ្វើបានក៏ដោយ ក៏ការអនុវត្តជាក់ស្តែងចំពោះប្រភេទចំណាយមួយចំនួនមានការលំបាកក្នុងការចំណាយទៅតាមកម្មវិធី។ **ឧទាហរណ៍÷** ចំណាយលើបុគ្គលិក ដែលករណីខ្លះបុគ្គលិកម្នាក់អាចមានការទទួលខុសត្រូវចំពោះកម្មវិធី ឬចង្កោមសកម្មភាព ច្រើនជាងមួយ។ ក្នុងករណីនេះ ដើម្បីអាចបំបែកចំណាយលើបុគ្គលិកម្នាក់ទៅតាមកម្មវិធី ឬចង្កោមសកម្មភាពនីមួយៗបានលុះត្រាតែអាចគណនាទៅតាមចំនួនម៉ោងដែលបុគ្គលនោះចំណាយជាក់ស្តែងទៅតាមចង្កោមសកម្មភាពតាមកម្មវិធីនីមួយៗ។ ការធ្វើដូចនេះ អាចចំណាយពេលច្រើន ហើយក៏ពុំទាន់ចាំបាច់សម្រាប់ការអនុវត្តថវិកាកម្មវិធីនៅក្នុងដំណាក់កាលនេះទេ។ ***ដូច្នេះ ប្រាក់បៀវត្សមិនគួរធ្វើការបែងចែកទៅតាមកម្មវិធី ឬចង្កោមសកម្មភាពនោះទេ។***

នៅក្នុងការប្រមូលព័ត៌មានស្តីពីការចំណាយដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ជាធម្មតាថ្លៃចំណាយអាចមានភាពខុសគ្នាទៅតាមតំបន់ ឬភូមិសាស្ត្រនីមួយៗ ជាពិសេស ថ្លៃដឹកជញ្ជូន និងថ្លៃពលកម្មជាដើម។ ទោះជាយ៉ាងនេះក្តី ការចំណាយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាមួយចំនួន យើងអាចកសាងឱ្យមានលក្ខណៈជាស្តង់ដារសម្រាប់ប្រើប្រាស់គ្រប់តំបន់បាន។ ចំពោះការចំណាយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាមួយចំនួនដែលមិនអាចរៀបចំឱ្យមានលក្ខណៈស្តង់ដារបាន អង្គភាពចំណាយគួរបង្កើតឱ្យមានទិន្នន័យថ្លៃ (cost database) ដើម្បីជាមូលដ្ឋានសម្រាប់គណនាថ្លៃចំណាយទៅតាមតំបន់នីមួយៗ ដូចជា ថ្លៃចំណាយសម្រាប់ការិយាល័យរដ្ឋបាល និងផ្សេងៗ។

### *ក. ការគណនាតម្រូវការចំណាយដោយផ្អែកលើធាតុចូល*

ការគណនាចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ចែកចេញជាពីរប្រភេទគឺ ចំណាយចរន្ត និងចំណាយមូលធន ដូចបានបង្ហាញក្នុងតារាងទី ១៥ ខាងក្រោម÷

***តារាងទី១៥÷ ការចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា***

| **ចំណាយ** | **ប្រភេទចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា** |
|---|---|
| **ចំណាយចរន្ត** | ជាចំណាយលើជំពូក៦០,៦១,៦២,៦៣,៦៤ និងជំពូក៦៥។ **ឧទាហរណ៍÷** ការចំណាយលើអគ្គិសនី, ទឹក, ការជួសជុល និងថែទាំអគារ, ប្រេងឥន្ធនៈ, ការថែទាំយានយន្ត,ការធានារ៉ាប់រងយានយន្ត, សម្ភារការិយាល័យ (ក្រដាស ទឹកថ្នាំ ព្រីនធ័រ), ទូរស័ព្ទ, បណ្តុះបណ្តាលបុគ្គលិក, ការប្រជុំ, សិក្ខាសាលា និងបេសកកម្ម ។ល។ |

| | |
|---|---|
| **ចំណាយមូលធន** | ជាចំណាយលើជំពូក២០ និង២១។ **ឧទាហរណ៍÷** ការវិនិយោគសាធារណៈ រួមមាន ការសាងសង់អគារ, ការកែលម្អអគារទ្រង់ទ្រាយធំ, ការកសាងប្រព័ន្ធធារាសាស្ត្រ និងផ្លូវថ្នល់។ ទ្រព្យសម្ភារៈមួយចំនួនផ្សេងទៀតក៏ជាប្រភេទមូលធនដែរ ដូចជា យានយន្ត , គ្រឿងចក្រ ជាដើមដែលមានកម្រិតកំណត់ទឹកប្រាក់ និងអាយុកាលនៃការប្រើប្រាស់ទៅតាមចំណាយបែបមូលធន។ |

ដើម្បីជាមូលដ្ឋានក្នុងការគ្រោងចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាសម្រាប់ឆ្នាំខាងមុខ រដ្ឋបាលរាជធានី ខេត្ត អាចប្រើប្រាស់ការគ្រោងចំណាយឆ្នាំមុនៗ ដែលមានលក្ខណៈស្រដៀងគ្នា។ ផ្ទុយមកវិញ ប្រសិនបើគ្មានព័តិមានអំពីថ្លៃចំណាយនៅឆ្នាំកន្លងមក រដ្ឋបាលរាជធានី ខេត្ត អាចប្រើប្រាស់ព័តិមានថ្លៃចំណាយតាមរយៈតារាងថ្លៃ (Quotation) ពីបណ្តាអ្នកផ្គត់ផ្គង់ផ្សេងៗ។ **ឧទាហរណ៍** តារាងទី១៦ខាងក្រោម បង្ហាញអំពីការគណនាថ្លៃចំណាយនៅកម្រិតចង្កោមសកម្មភាព។

***តារាងទី១៦÷ ការគណនាថ្លៃចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា***

| | **ចង្កោមសកម្មភាពទី១: ការរៀបចំសេចក្តីព្រាងច្បាប់** | **ចំណាយជាក់ស្តែងឆ្នាំ២០១៥** (លានរៀល) | **សកម្មភាពដែលត្រូវអនុវត្តឆ្នាំ២០១៦** | **តម្រូវការថវិកាឆ្នាំ២០១៦** (លានរៀល) |
|---|---|---|---|---|
| ១.១ | ប្រជុំ (អ្នកចូលរួម២០នាក់ដើម្បីព្រាងច្បាប់ចំនួន ៤ រៀងរាល់សប្តាហ៍។ ច្បាប់នីមួយៗត្រូវការប្រជុំចំនួន២ លើកក្នុងមួយសប្តាហ៍ដូច្នេះយើងមានកិច្ចប្រជុំចំនួន៨ លើកក្នុងមួយសប្តាហ៍។ ដូចនេះ ៥០០០រៀល x២០ នាក់ x៤១៦លើក/ឆ្នាំ= ៤១៦០០០០០រៀល) | ៣១,២ | កិច្ចប្រជុំចំនួន៤១៦ លើកមួយឆ្នាំ | ៤១,៦០ |
| ១.២ | សិក្ខាសាលាស្តីពីសេចក្តីព្រាងច្បាប់÷ សេចក្តីព្រាងច្បាប់ចំនួន៤សេក្តីព្រាងនីមួយៗត្រូវការសិក្ខាសាលាចំនួន ១ ក្នុងមួយឆ្នាំ។ ដូច្នេះ មានសិក្ខាសាលាសរុបចំនួន៤ក្នុងមួយឆ្នាំ( សិក្ខាសាលានីមួយៗមានអ្នកចូលរួមចំនួន | | សិក្ខាសាលា ៤ដងក្នុង១ឆ្នាំ | ១២៧.២៨ |

| | | | | |
|---|---|---|---|---|
| | ១០០នាក់ ហើយមានរយៈពេលបីថ្ងៃ) | | | |
| ១.៣ | សម្ភារៈបរិក្ខារ<br>១. ការថតចម្លង = ៤១.០លាន<br>២. ការជួលកុំព្យូទ័រ និងព្រីនធ័រ (២)<br>៨.២លាន x២ =១៦.៤លាន<br>សរុប = ៥៧.៤០លាន | | | ៥៧.៤០ |
| | **សរុប (១.១ +១.២+១.៣)** | | | **២២៦.២៨** |

### *ខ. ការគណនាតម្រូវការចំណាយដោយផ្អែកតាមកម្មវិធី*

ការកំណត់ថ្លៃចំណាយដោយផ្អែកតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ ដែលបានអនុវត្តកន្លងមក។ **ឧទាហរណ៍**÷ រដ្ឋបាលខេត្តព្រៃវែងមានគោលដៅសាងសង់ផ្លូវ BST នៅក្នុងក្រុងនៃរដ្ឋបាលខេត្តរបស់ខ្លួន ដែលបច្ចុប្បន្នមានផ្លូវចំនួន ៦០% ហើយជាគោលដៅ គឺឱ្យទៅដល់ ៧០% នៅឆ្នាំទី១ ៨០% នៅឆ្នាំទី២ និង ៩០% នៅឆ្នាំទី៣។ ដូច្នេះ លទ្ធផលក្នុងឆ្នាំ គឺជាប្រវែងផ្លូវដែលត្រូវបានសាងសង់ និងលទ្ធផលចុងក្រោយ គឺការកាត់បន្ថយការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

នៅក្នុងការគណនាពីតម្លៃនៃការសាងសង់ផ្លូវ BST គឺត្រូវផ្អែកលើតម្លៃប៉ាន់ស្មាន ដែលអនុវត្តកន្លងមក (ឆ្នាំចាស់)។ មុខសញ្ញាចំណាយ ដែលត្រូវគណនាដើម្បីអនុវត្តការសាងសង់ផ្លូវ BST នេះ អាចចែកចេញជា ៣ ប្រភេទដូចខាងក្រោម ÷

*១. **ចំណាយរដ្ឋបាល***÷ ជាចំណាយប្រតិបត្តិការរបស់ការិយាល័យអនុវត្តគម្រោងសាងសង់ផ្លូវ។

*២. **ចំណាយសេវា*** ÷ ជាចំណាយទៅលើសកម្មភាព ដូចជាការសិក្សាប្លង់ ការពិភាក្សាជាមួយសហគមន៍ និងការពិគ្រោះយោបល់ផ្ទាល់ជាមួយអ្នកបច្ចេកទេសសាងសង់ជាដើម ។

*៣. **ចំណាយវិនិយោគ***÷ ជាចំណាយលើការសាងសង់ ដែលស្ថិតក្នុងចំណាត់ថ្នាក់ចំណាយមូលធន។

តារាងទី ១៧ ខាងក្រោមបង្ហាញពីវិធីសាស្ត្រក្នុងការកំណត់តម្រូវការធាតុចូល និងការគណនាថ្លៃចំណាយសម្រាប់ធាតុចូល។

*តារាងទី ១៧÷ ការកំណត់ធាតុចូល និង គណនាថ្លៃចំណាយសម្រាប់ធាតុចូល*

| | **ធាតុចូល** | | | | **ធាតុចូល** | | | | |
|---|---|---|---|---|---|---|---|---|---|
| **ចំណាយរដ្ឋបាល** | | | | | | | | | **ឯកតា:លានរៀល** |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| | ក្រដាស | | | | ទឹក | | | | |
| | ប៊ិច | | | | អគ្គិសនី | | | | |
| | | | | | ទូរសព្ទ័ | | | | |
| សរុប | | | | | | | | | |
| **ចំណាយសេវា** | | | | | | | | **ឯកតា:លានរៀល** | |
| | **ថ្លៃធ្វើដំណើរ** | | | | **សម្ភារៈការិយាល័យ** | | | | |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| ការសិក្សាប្លង់ | ប្រេង | | | | | | | | |
| ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ | | | | | | | | | |
| ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ | | | | | | | | | |
| សរុប | | | | | | | | | |
| **ចំណាយវិនិយោគ** | | | | | | | | | **ឯកតា:លានរៀល** |
| | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | ប្រភេទ | បរិមាណ | ថ្លៃ | សរុប | សរុបរួម |
| ចំណាយមូលធន | | | | | | | | | |

ក្រោយពីបានកំណត់ និងគណនាថ្លៃចំណាយសម្រាប់សកម្មភាពនីមួយៗរួច ជំហានបន្ទាប់ត្រូវយកថ្លៃចំណាយសម្រាប់សកម្មភាពនីមួយៗនេះ ទៅគុណនឹងសកម្មភាពសរុបដែលបានកំណត់សម្រាប់ការអនុវត្តក្នុងឆ្នាំនីមួយៗដូចមានបង្ហាញនៅក្នុងតារាងទី ១៧ ខាងលើ។ ជាលទ្ធផល យើងនឹងបានថ្លៃចំណាយសម្រាប់រយៈពេល ៣ឆ្នាំ ដូចបង្ហាញក្នុងតារាងទី ១៨ ខាងក្រោម÷

*តារាងទី ១៨÷ ថ្លៃចំណាយសម្រាប់ចង្កោមសកម្មភាពក្នុងរយៈពេល៣ឆ្នាំ*

| | ឆ្នាំទី១ | | | ឆ្នាំទី២ | | | ឆ្នាំទី៣ | | |
|---|---|---|---|---|---|---|---|---|---|
| | សកម្មភាពការងារ | ថ្លៃ | សរុប | សកម្មភាពការងារ | ថ្លៃ | សរុប | សកម្មភាពការងារ | ថ្លៃ | សរុប |
| **១. រដ្ឋបាល** | | | | | | | | | |
| **២. សេវា** | | | | | | | | | |
| សិក្សាប្លង់ | | | | | | | | | |
| ជួបជាមួយប្រជាពលរដ្ឋ | | | | | | | | | |
| ជួបអ្នកជំនាញ | | | | | | | | | |
| **៣. វិនិយោគ** | | | | | | | | | |
| **សរុប (១+២+៣)** | | | | | | | | | |

*សំគាល់÷ ថ្លៃចំណាយខាងលើនេះ គឺគណនាទៅតាមតម្លៃជាក់ស្តែងនៅលើទីផ្សារដោយមិនគិតពីអតិផរណាដែលអាចកើតមានឡើងនោះទេ។ កត្តាអតិផរណានឹងធ្វើការគិតគូរដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

នៅពេលដែលបានកំណត់ពីថ្លៃចំណាយរួចហើយ គឺត្រូវធ្វើការចោទសួរ ដូចខាងក្រោម÷

- តើធាតុចូល និងការចំណាយសម្រាប់អនុវត្តសកម្មភាព ដែលបានកំណត់មានលក្ខណៈត្រឹមត្រូវឬទេ? បើធៀបនឹងធាតុចូល និងការចំណាយផ្សេងៗទៀត។
- តើការកំណត់អំពីប្រភេទ និងបរិមាណនៃធាតុចូលសម្រាប់អនុវត្តសកម្មភាពបានត្រឹមត្រូវដែរឬទេ?
- តើមានសកម្មភាព ឬធាតុចូលមានត្រួតគ្នាដែរឬទេ?
- តើមានជម្រើសដើម្បីកាត់បន្ថយការចំណាយដែរឬទេ?
- តើធាតុចូលសម្រាប់អនុវត្តសកម្មភាពទាំងអស់ ដែលបានកំណត់ជាតម្រូវការចាំបាច់ដែរឬទេ? បើធ្វើការកាត់បន្ថយចំនួនធាតុចូល តើនៅតែអាចសម្រេចបានលទ្ធផលបានដូចគ្នាឬទេ?
- តើមានតុល្យភាពដែរឬទេ រវាងចំណាយសម្រាប់ដំណើរការរដ្ឋបាល និងការផ្តល់សេវា?

***សំគាល់÷ តារាងទី១៦, ១៧ និង១៨ ខាងលើ គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ គំរូតារាងរបាយការណ៍ចំណាយមានជូនភ្ជាប់ក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីដែលប្រកាសដាក់ឱ្យប្រើប្រាស់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។***

### ៣.៨ ជំហានទី៨- ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង

*(ជំហានទី ៨ មានសារសំខាន់ ដើម្បីពិនិត្យឡើងវិញភាពសមស្រប និង តក្កភាពនៃសង្វាក់លទ្ធភាពដែលបានកសាងតារាងឧបសម្ព័ន្ធទី ១.១, ១.២ , ១.៣, ១.៤, ១.៥, ១.៦, ១.៧, ១.៨ និង១.៩)*

បន្ទាប់ពីរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពត្រូវបានកំណត់, ផែនការចំណូល និងចំណាយសម្រាប់ការអនុវត្តត្រូវបានគណនា, និងសូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវបានជ្រើសរើសរួច គឺចាំបាច់ត្រូវពិនិត្យមើលឡើងវិញទៅលើឡូជីក (Logic) នៃខ្សែសង្វាក់លទ្ធផលរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព។

គោលបំណង គឺដើម្បីពិនិត្យមើលឱ្យប្រាកដថា÷

- ✓ មានធាតុចូលដែលអាចអនុវត្តចង្កោមសកម្មភាព
- ✓ មានចង្កោមសកម្មភាពដើម្បីសម្រេចលទ្ធផលក្នុងឆ្នាំ
- ✓ មានលទ្ធផលក្នុងឆ្នាំដើម្បីសម្រេចលទ្ធផលចុងក្រោយនៃកម្មវិធីនីមួយៗ
- ✓ មានលទ្ធផលចុងក្រោយដែលអាចសម្រេចគោលបំណងនៃកម្មវិធីនីមួយៗ
- ✓ មានគោលបំណងនៃកម្មវិធីដើម្បីរួមចំណែកសម្រេចគោលបំណងគោលនយោបាយ
- ✓ មានព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានសមិទ្ធកម្មដែលអាចធ្វើការតាមដាន និងធ្វើរបាយការណ៍បាន
- ✓ មានលទ្ធផលចុងក្រោយនៃកម្មវិធីដែលអាចយកមកធ្វើការវាយតម្លៃបាន។

ការពិនិត្យមើលឡើងវិញនេះ មានសារៈសំខាន់ណាស់ ព្រោះជាឱកាសមួយដើម្បីចោទសួរថា តើខ្សែ-សង្វាក់លទ្ធផល ដែលមាននៅក្នុងកម្មវិធីពិតជានឹងអាចសម្រេចគោលបំណងនៃកម្មវិធីបានឬយ៉ាងណា? ហើយអាចឱ្យយើងធ្វើការវាយតម្លៃឡើងវិញអំពីទិដ្ឋភាពពាក់ព័ន្ធទាំងអស់នៃកម្មវិធី។ ប្រសិនបើការពិនិត្យមើលឡើងវិញបង្ហាញថា ពុំមានសង្គតិភាព នោះកម្មវិធីគួរតែកែសម្រួលម្តងទៀត។ ដូចបានបង្ហាញក្នុងតារាងទី១៩ ខាងក្រោម ក្របខ័ណ្ឌឡូជីក (Logic) ផ្តល់នូវអត្ថប្រយោជន៍ក្នុងការវាយតម្លៃការផ្សារភ្ជាប់ទំនាក់ទំនងរវាងធាតុចូល, ការអនុវត្តចង្កោមសកម្មភាព និងការសម្រេចលទ្ធផលក្នុងឆ្នាំ, លទ្ធផលចុងក្រោយ និងគោលបំណងកម្មវិធី។

*តារាងទី១៩៖ ក្របខណ្ឌឡូជីក (Logic) ដើម្បីពិនិត្យមើលភាពគ្រប់ជ្រុងជ្រោយនៃរចនាសម្ព័ន្ធកម្មវិធី និង សូចនាករសមិទ្ធកម្ម*

| **កម្មវិធីទី........** | | **រៀបចំនៅថ្ងៃទី.............** | |
|---|---|---|---|
| **រចនាសម្ព័ន្ធនៃកម្មវិធី** | **សូចនាករ សមិទ្ធកម្មគន្លឹះ** | **សូចនាករសមិទ្ធកម្ម គន្លឹះដែលអាច ផ្ទៀងផ្ទាត់បាន** | **ការសន្មត** |
| **គោលបំណង** | | | |
| -តើគោលបំណងគោលនយោបាយដែលកម្មវិធីនឹងរួមចំណែកសម្រេចត្រូវបានកំណត់ច្បាស់លាស់ និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគោលបំណងនៃកម្មវិធីដែរឬទេ?<br>-តើគោលបំណងនៃអនុកម្មវិធីមានសង្គតិភាពជាមួយនឹងកម្មវិធី និងគោលបំណងគោលនយោបាយដែរឬទេ? | -តើ KPI ដែលមានលក្ខណៈ SMART ត្រូវបានកំណត់ដើម្បីវាយតម្លៃការសម្រេចគោលបំណងកម្មវិធីដែរឬទេ? | -កំណត់ប្រភពទិន្នន័យដែលអាចវាស់វែង KPI<br>-តើអាចប្រមូលទិន្នន័យសមស្របតាមកាលកំណត់ដែរឬទេ?<br>-តើមន្ត្រីធ្លាប់ត្រូវបានចាត់តាំងឱ្យប្រមូល រក្សាទុក ទាញយក វិភាគ និងប្រើប្រាស់ទិន្នន័យសមិទ្ធកម្មដែរឬទេ? | -តើមានលក្ខខណ្ឌខាងក្រៅដែលចាំបាច់អាចកំណត់បានដើម្បីសម្រេចគោលបំណងដែរឬទេ?<br>-តើហានិភ័យចំពោះស្ថិរភាពដោយសារតែកត្តាខាងក្រៅអាចសម្រាលបានដែរឬទេ? |
| **លទ្ធផលចុងក្រោយ** | | | |
| -តើលទ្ធផលរំពឹងទុកមានអ្វីខ្លះ?<br>-តើលទ្ធផលរំពឹងទុកអាចសម្រេចលទ្ធផលចុងក្រោយដែរឬទេ?<br>-តើលទ្ធផលចុងក្រោយត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងបែបតក្កៈជាមួយនឹងគោលបំណងកម្មវិធី និងជាមួយនឹងគោលបំណងគោលនយោបាយដែរឬទេ? | -តើ KPI ដែលមានលក្ខណៈ SMART ត្រូវបានកំណត់ដើម្បីវាយតម្លៃការសម្រេចគោលបំណងកម្មវិធីដែរឬទេ? | -កំណត់ប្រភពទិន្នន័យដែលអាចវាស់វែង KPI<br>-តើអាចប្រមូលទិន្នន័យសមស្របតាមកាលកំណត់ដែរឬទេ?<br>-តើមន្ត្រីធ្លាប់ត្រូវបានចាត់តាំងឱ្យប្រមូល រក្សាទុក ទាញយក វិភាគ និងប្រើប្រាស់ទិន្នន័យសមិទ្ធ- | -តើមានលក្ខខណ្ឌខាងក្រៅដែលចាំបាច់អាចកំណត់បាន ដើម្បីសម្រេចគោលបំណងដែរឬទេ?<br>-តើហានិភ័យចំពោះស្ថិរភាពដែលកើតឡើងដោយសារតែកត្តាខាងក្រៅអាចសម្រាលបាន |

| | | | |
|---|---|---|---|
| | | កម្មដែរឬទេ? | ដែរឬទេ? |
| **លទ្ធផលក្នុងឆ្នាំ** | | | |
| -តើអ្វីខ្លះនឹងផលិត ដើម្បីសម្រេចលទ្ធផលចុងក្រោយ? តើលទ្ធផលក្នុងឆ្នាំទាំងនេះនឹងនាំឱ្យសម្រេចលទ្ធផលចុងក្រោយដែរឬទេ? | -តើ KPI ដែលមានលក្ខណៈ SMART ត្រូវបានកំណត់ដើម្បីវាយតម្លៃការសម្រេចលទ្ធផលក្នុងឆ្នាំដែរឬទេ?<br><br>-តើប្រភេទ បរិមាណ គុណភាព និងពេលវេលាកំណត់នៃលទ្ធផលក្នុងឆ្នាំអាចសម្រេចលទ្ធផលចុងក្រោយបានដែរឬទេ?<br><br>-តើ KPI Target មានលក្ខណៈសមស្របចំពោះ KPI ដែរឬទេ? | -តើមានប្រភពទិន្នន័យដែលអាចកំណត់បានដើម្បីវាស់វែង និងរាយ-ការណ៍អំពី KPI ដើម្បីផ្តល់លទ្ធផលក្នុងឆ្នាំដែរឬទេ?<br><br>-តើអាចប្រមូលទិន្នន័យសមស្របតាមកាលកំណត់ដែរឬទេ?<br><br>-តើមន្ត្រីធ្លាប់ត្រូវបានចាត់តាំងឱ្យប្រមូល រក្សាទុក ទាញយក វិភាគ និងប្រើប្រាស់ទិន្នន័យសមិទ្ធ-កម្មដែរឬទេ? | -តើកត្តាអ្វីខ្លះដែលអាចរឹតត្បិតលទ្ធផលក្នុងឆ្នាំមិនឱ្យសម្រេចលទ្ធផលចុងក្រោយ?<br><br>-តើហានិភ័យចំពោះស្ថិរ-ភាពដែលកើតឡើងដោយសារតែកត្តាខាងក្រៅអាចសម្រាលបានដែរឬទេ? |
| **ចង្កោមសកម្មភាព** | | | |
| -ចង្កោមសកម្មភាពអាចមានចំនួនច្រើនដើម្បីសម្រេចបានអនុកម្មវិធីមួយ | -ចង្កោមសកម្មភាពមួយត្រូវមានសូចនាករលទ្ធផលក្នុងឆ្នាំមួយយ៉ាងតិចសម្រាប់វាស់វែងការអនុវត្តប្រចាំឆ្នាំ | | |
| **សកម្មភាព** | | | |
| -តើសកម្មភាពអ្វីខ្លះនឹងត្រូវអនុវត្តដើម្បីផលិតលទ្ធផលក្នុងឆ្នាំ?<br><br>-តើសកម្មភាពត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងបែបតក្កៈដើម្បីផ្តល់ | -តើមានការកំណត់ច្បាស់លាស់ពាក់ព័ន្ធពេលវេលាអនុវត្តសកម្មភាពពេលបញ្ចប់និងដោយនរណាដែរ | -កំណត់ប្រភពទិន្នន័យដែលអាចវាស់វែង KPI តើអាចប្រមូលទិន្នន័យសមស្របតាមកាល | -តើកត្តាអ្វីខ្លះដែលអាចរឹតត្បិតសកម្មភាពមិនឱ្យសម្រេចលទ្ធផលចុងក្រោយ?<br>-តើហានិភ័យអាច |

| | | | |
|---|---|---|---|
| នូវលទ្ធផលក្នុងឆ្នាំដែរទេ?<br><br>-តើសកម្មភាពមួយមានគោល-បំណងច្បាស់លាស់ដែរឬទេ? | ឬទេ?<br><br>-តើសកម្មភាពមួយមានគោលបំណងច្បាស់លាស់ដែរឬទេ? | កំណត់ដែរឬទេ?<br><br>-តើមន្ត្រីធ្លាប់ត្រូវបានចាត់តាំងឱ្យប្រមូល រក្សាទុក ទាញយក វិភាគ និងប្រើប្រាស់ទិន្នន័យសមិទ្ធ-កម្មដែរឬទេ? | សម្រាលបានដែរឬទេ និងដោយរបៀបណា? |
| **ធាតុចូល** | | | |
| -តើធនធានហិរញ្ញវត្ថុ និងធនធានផ្សេងទៀតអ្វីខ្លះដែលនឹងត្រូវការជាចាំបាច់ដើម្បីអនុវត្តចង្កោមសកម្មភាព?<br><br>-តើចង្កោមសកម្មភាពទាំងអស់ត្រូវបានគណនាថ្លៃចំណាយសម្រាប់រយៈពេលបីឆ្នាំដែរឬទេ?<br><br>-តើចង្កោមសកម្មភាពដែលបានគណនាការចំណាយមានចំនួនស្ថិតនៅក្នុងកម្រិតពិតានថវិកាសម្រាប់ខេត្តដែរឬទេ? | -តើមានបានបង្កើតផែនការលទ្ធកម្មដែលមានប្រសិទ្ធភាពដែរឬទេ?<br><br>-តើផែនការនេះមានបង្ហាញច្បាស់លាស់ថាតើធនធានអ្វីខ្លះនឹងត្រូវផ្គត់ផ្គង់ និងលក្ខណៈបច្ចេកទេសនៃបរិមាណ គុណភាព ពេលវេលា និងថ្លៃចំណាយដែរឬទេ? | -តើប្រភពទិន្នន័យអំពីការប្រើប្រាស់ថវិកាអាចធ្វើការផ្ទៀងផ្ទាត់បានដែរ ឬទេ ហើយតើមានប្រព័ន្ធរាយការណ៍មានប្រសិទ្ធភាពដែរឬទេ? | -តើកត្តាអ្វីខ្លះនឹងរឹតត្បិតដល់ការផ្គត់ផ្គង់ធាតុចូល?<br><br>-តើហានិភ័យអាចសម្រាលបានដែរឬទេ និងដោយរបៀបណា? |

*បន្ទាប់ពីបានបញ្ចប់ជំហានទី១ រហូតដល់ជំហានទី៨នេះ រដ្ឋបាលរាជធានី ខេត្តបានបញ្ចប់ការរៀបចំផែនការថវិកាកម្មវិធីប្រចាំឆ្នាំហើយ។ ជំហានបន្ទាប់ គឺត្រូវដាក់ផែនការថវិកាកម្មវិធីប្រចាំឆ្នាំជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច រួចផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តទៅតាមពេលវេលាកំណត់ ដែលមានចែងនៅក្នុងសារាចរណែនាំស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ។ រដ្ឋបាលរាជធានី ខេត្តមានកាតព្វកិច្ចពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធីពីមួយឆ្នាំទៅមួយឆ្នាំដើម្បីធានាថា ថវិកាកម្មវិធីដែលបានកសាងអាចសម្រេចយុទ្ធសាស្ត្រអាទិភាព ក៏ដូចជាគោលនយោបាយរបស់ខ្លួន។ ក្នុងករណីមានការចាំបាច់ក្នុងការកែសម្រួលរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។*

# ផ្នែកទី ៤
# ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី

នៅរៀងរាល់ឆ្នាំនីមួយៗ រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី ទៅតាមទម្រង់បែបបទ ដែលមាននៅក្នុងឧបសម្ព័ន្ធទី២។ រដ្ឋបាលរាជធានី ខេត្តត្រូវបង្កើតយន្តការ និងនីតិវិធី សម្រាប់ពិនិត្យតាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ***ផ្នែកនេះនឹងផ្ដល់នូវសេចក្ដីពន្យល់ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី២.១ ដល់ ២.១០។*** ទម្រង់របាយការណ៍ចែកជាពីរប្រភេទ÷ទី១-របាយការណ៍ហិរញ្ញវត្ថុ និងទី២-របាយការណ៍វឌ្ឍនភាពដែលឆ្លុះបញ្ចាំងពីសូចនាករសមិទ្ធកម្មសម្រាប់កម្មវិធី។

### ទី១- របាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តថវិកាកម្មវិធី

របាយការណ៍ហិរញ្ញវត្ថុ គឺឆ្លុះបញ្ចាំងអំពីកិច្ចដំណើរការដែលរដ្ឋបាលរាជធានី ខេត្តគ្រប់គ្រង និងចាត់ចែងធនធានថវិការបស់ខ្លួន។ របាយការណ៍ហិរញ្ញវត្ថុវិភាគអំពីស្ថានភាពអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា (ជំពូក គណនី និងអនុគណនី) ដោយបង្ហាញព័ត៌មានអំពីកញ្ចប់ឥណទានថវិកា ដែលត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ ការធ្វើចលនាឥណទានថវិកា ការប្រើប្រាស់ និងសមតុល្យឥណទានថវិកាទាំងការធានាចំណាយ និងទាំងការបោះផ្សាយអាណត្តិបើកប្រាក់ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ របាយការណ៍ហិរញ្ញវត្ថុក៏ត្រូវបង្ហាញអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំសារពើពន្ធធៀប ជាមួយនឹងលទ្ធផលអនុវត្តនៅឆ្នាំមុនៗ។

រដ្ឋបាលរាជធានី ខេត្តតម្រូវឱ្យធ្វើរបាយការណ៍តាមគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍នីមួយៗដូចមានភ្ជាប់នៅក្នុងតារាងឧបសម្ព័ន្ធទី២.១ ដល់ ២.៧។ របាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការិយបរិច្ឆេទដូចខាងក្រោម÷

- របាយការណ៍ចំណូល-ចំណាយប្រចាំខែតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុត ត្រឹមថ្ងៃទី១០ ខែបន្ទាប់។
- របាយការណ៍ចំណាយប្រចាំត្រីមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែនាដើមត្រីមាសបន្ទាប់។

- របាយការណ៍ចំណាយប្រចាំឆមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ។
- របាយការណ៍ចំណូល-ចំណាយសម្រាប់ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា។
- របាយការណ៍ចំណូល-ចំណាយប្រចាំឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករានៃឆ្នាំបន្ទាប់។
- របាយការណ៍ចំណាយប្រចាំឆ្នាំនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករានៃឆ្នាំបន្ទាប់។

**ទី ២- របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធី**

របាយការណ៍សមិទ្ធកម្ម គឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផល និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធី អនុវកម្មវិធី និង ចង្កោមសកម្មភាព ដើម្បីឈានឆ្ពោះទៅសម្រេចគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទម្រង់នៃរបាយការណ៍នេះ ផ្តល់ជូនក្នុងឧបសម្ព័ន្ធទី២តារាងទី២.៨ និងទី២.១០។

របាយការណ៍សមិទ្ធកម្មត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ តាមកាលវិភាគ/កាលបរិច្ឆេទដូចខាងក្រោម÷

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាសត្រូវផ្ញើមកយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមករានៃឆ្នាំបន្ទាប់។

ជាសរុប ការណែនាំពីជំហានទី១ ដល់ជំហានទី៨ បង្ហាញអំពីដំណើរការកសាងផែនការថវិកាកម្មវិធី។ នីតិវិធីនៃការអនុវត្តថវិកាកម្មវិធីដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត នឹងផ្អែកតាមគោលការណ៍ណែនាំដោយឡែកហៅថា «**នីតិវិធីអនុវត្តថវិកាកម្មវិធី**» ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ផ្នែកទី៥

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល...................**

**គម្រោងថវិកាកម្មវិធីឆ្នាំ.....**

**តារាងឧបសម្ព័ន្ធ ១.១**

ឯកតា:លានរៀល

| ការកំណត់គោលបំណង និងការទទួលខុសត្រូវ | | |
|---|---|---|
| **បរិយាយ** | **អង្គភាព/អ្នកទទួលខុសត្រូវ (កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព)** | **ការពិពណ៌នាអំពីគោលបំណង (អនុកម្មវិធី ចង្កោមសកម្មភាព)** |
| ១. កម្មវិធីទី១................................ | | |
| ១.១. អនុកម្មវិធីទី១...................... | | |
| ១.១.១. ចង្កោមសកម្មភាពទី១.......... | | |
| ១.១.១.១ សកម្មភាពទី១......... | | |
| ២. កម្មវិធីទី២....... | | |
| ២.១ អនុកម្មវិធីទី១.................... | | |
| ២.១.១ ចង្កោមសកម្មភាពទី១......... | | |
| ២.១.១.១ សកម្មភាពទី១ | | |
| ២.១.១.២ សកម្មភាពទី២ | | |

បានឃើញ និង ឯកភាព
រដ្ឋបាល.........ថ្ងៃទី.........ខែ....... ឆ្នាំ........
**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
រដ្ឋបាល........ថ្ងៃទី.......ខែ....... ឆ្នាំ.......
**នាយកទីចាត់ការហិរញ្ញវត្ថុ**

រដ្ឋបាល.......ថ្ងៃទី........ខែ........ ឆ្នាំ.........
**អ្នករៀបចំតារាង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល........................**

**គម្រោងថវិកាកម្មវិធីឆ្នាំ........**

**តារាងឧបសម្ព័ន្ធ ១.២**

ឯកតា:លានរៀល

| **វឌ្ឍនភាពសូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករសមិទ្ធកម្មនៃកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព** | | | | | |
|---|---|---|---|---|---|
| **បរិយាយ** | សូចនាករ លទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | | |
| | | ឆ្នាំ........... (ឆ្នាំកំពុងអនុវត្ត) | | ឆ្នាំ....................... (ឆ្នាំបន្ទាប់) | |
| | | គោលដៅ | សម្រេចឆមាសទី១ | គោលដៅ | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល |
| ១. កម្មវិធីទី១................................ | | | | | |
| ១.១. អនុកម្មវិធីទី១...................... | | | | | |
| ១.១.១. ចង្កោមសកម្មភាពទី១.......... | | | | | |
| ១.១.១.១ សកម្មភាពទី១......... | | | | | |
| ២. កម្មវិធីទី២....... | | | | | |
| ២.១ អនុកម្មវិធីទី១.................... | | | | | |
| ២.១.១ ចង្កោមសកម្មភាពទី១......... | | | | | |

បានឃើញ និងឯកភាព
រដ្ឋបាល........ថ្ងៃទី........ខែ....... ឆ្នាំ........
**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

បានឃើញ និងពិនិត្យត្រឹមត្រូវ
រដ្ឋបាល.......ថ្ងៃទី.........ខែ....... ឆ្នាំ........
**នាយកទីចាត់ការហិរញ្ញវត្ថុ**

រដ្ឋបាល.........ថ្ងៃទី........ខែ........ ឆ្នាំ.........
**អ្នករៀបចំតារាង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាល....

## គម្រោងថវិកាកម្មវិធីឆ្នាំ.........

## សូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករសមិទ្ធកម្ម

តារាងឧបសម្ព័ន្ធ ១.៣

ឯកតា:លានរៀល

| **បរិយាយ** | ឥណទាន | លទ្ធផលក្នុងឆ្នាំ (Output) (ឆ្នាំ n+1) | | លទ្ធលផលចុងក្រោយ (Outcome) | |
|---|---|---|---|---|---|
